ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៧ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រឹត្យ

១៩-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/១១	២៥៨
១៩-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/១២	២៦១
២៥-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/១៦	២៦៨
២៥-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/១៧	២៧៨
២៥-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/១៨	២៧៩
២៥-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/១៩	២៧៩
២៦-២-១៩៩៥	-ព្រះរាជក្រឹត្យ លេខ នស/រកត/០២.៩៥/២០	២៨៥

II- ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១៥-២-១៩៩៥	-អនុក្រឹត្យលេខ ១៧ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ	២៨៦
២០-២-១៩៩៥	-អនុក្រឹត្យលេខ ១៨ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៨៧
២០-២-១៩៩៥	-អនុក្រឹត្យលេខ ១៩ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៨៨
២០-២-១៩៩៥	-អនុក្រឹត្យលេខ ២០ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ	២៨៩
២២-២-១៩៩៥	-អនុក្រឹត្យលេខ ២១ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៩០
២៣-២-១៩៩៥	-អនុក្រឹត្យលេខ ២២ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៩១

២.សេចក្ដីសំរេច

១៨-២-១៩៩៥ -សេចក្ដីសំរេចលេខ ១៩ សសរ ស្ដីពីការផ្ទេរសិទ្ធិ ២៩៣

២៣-២-១៩៩៥ -សេចក្ដីសំរេចលេខ ២០ សសរ ស្ដីពីការបង្កើតក្រុមការងារ " TASK FORCE " ដើម្បីចរចាសំរបសំរួលការងារជាមួយក្រុមហ៊ុន ARISTON ២៩៤

III- ការងារបណ្ដាក្រសួង

១.ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សេចក្ដីណែនាំ-ប្រកាស

២២-២-១៩៩៥ -សេចក្ដីណែនាំលេខ ០៣២ សហវ ច.សណន ស្ដីពីការបើកប្រាក់បៀវត្សជូនមន្ត្រីរាជ ការស៊ីវិល តាមក្រសួង ស្ថាប័ន នៅរដ្ឋបាលកណ្ដាល និង តាមមន្ទីរនានានៅ ខេត្ត-ក្រុង ២៩៦

២៤-២-១៩៩៥ -ប្រកាសលេខ ០៣៣ ប្រក សហវ ធរ ស្ដីពីសេចក្ដីយល់ព្រមអោយក្រុមហ៊ុន INDOCHINE INSURANCE UNION សហការបច្ចេកទេសជាមួយកាមិនកូ ដើម្បីធានារ៉ាប់រងលើការអនុវត្តគំរោងរបស់អង្គការសហគមអឺរ៉ុប " PRASAC-3 " ២៩៨

២.ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

២៤-២-១៩៩៥ -ប្រកាសលេខ ០៧២ ពណ បល.ប្រក ស្ដីពីការប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្ដម ខៀវ រ៉ាដា ៣០០

៣.ទីស្ដីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

២០-២-១៩៩៥ -ប្រកាសលេខ ០៨៦ ប្រក.កសក ស្តីពីអាករអនាម័យសត្វ និងផលិតផល
មានដើមកំណើតពី សត្វ ៣០១
២៤-២-១៩៩៥ -ប្រកាសលេខ ០៩៣ ប្រក.កសក ស្តីពីការលក់វត្ថុតាងរឹបអូស នៃបទល្មើស
នេសាទសមុទ្រ ៣០៥

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១៧-២-១៩៩៥ -ប្រកាសលេខ ០៤៧/៩៥ ពម.ប្រក ៣០៧
១៨-២-១៩៩៥ -ប្រកាសលេខ ០៤៨/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការនៅ
មន្ទីរពត៌មាន ខេត្តកណ្តាល ៣០៨
១៨-២-១៩៩៥ -ប្រកាសលេខ ០៤៩/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការនៃ
មន្ទីរពត៌មាន ខេត្ត កំពង់ ចាម ៣០៩

៥-ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២០-២-១៩៩៥ -ប្រកាសលេខ ០៣៩ បទ.ប្រក ស្តីពីការតែងតាំងបជិត្តាហកៈ មន្ទីរ
ប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត បន្ទាយមានជ័យ ៣១០

៦-ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

២៤-២-១៩៩៥ -ប្រកាសលេខ ៤០២ ប.ស្ថ ស្តីពីការផ្ទេរភារកិច្ចជូនមន្ត្រីរាជការ ៣១១
២៤-២-១៩៩៥ -ប្រកាសលេខ ៤០៣ ប.ស្ថ ស្តីពីការតែងតាំងតួនាទីភារកិច្ច ៣១២

៧-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

២០-២-១៩៩៥ -ប្រកាសលេខ ៤០/៩៥ កធស .ប្រក ស្តីពីការទទួលស្គាល់សមាសភាពមន្ត្រី
រាជការ របស់ខេត្ត មណ្ឌលគិរី ៣១៣

២២-២-១៩៩៥ -ប្រកាសលេខ ៤៧/៩១ កធស.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣១៤

២២-២-១៩៩៥ -ប្រកាសលេខ ៤៨/៩៥ កធស.ប្រក ស្ដីពីការយល់ព្រមបញ្ចូលមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌមន្ទីរ ធម្មការ ខេត្តតាកែវ ៣១៥

៨- ប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ , ពាណិជ្ជកម្ម , រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

២៧-២-១៩៩៥ - ប្រកាសលេខ ១០០ ប្រក.កសក ស្ដីពីការកំណត់ថ្លៃឈើ និង ថ្លៃលក់-ទិញឈើ តាមមាត់ចក្រនាំចេញ ៣១៧

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យលេខ ន.ស./រកត/០២.៩៥/១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋ មន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣ នៃរាជរដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជា ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ ផ្នែកវប្បធម៌ជាតិ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និង វិចិត្រសិល្បៈរៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ និង ដោយគណៈរដ្ឋមន្ត្រីបានយល់ព្រមផង តាមរយៈការប្រជុំពេញអង្គ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសបង្គាប់

មាត្រា ១ : "ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ " ដែលបង្កើតឡើងតាមសេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣ នៃរាជរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជា មានសមាសភាពថ្មីដូចតទៅ ÷

១_នាយករដ្ឋមន្ត្រីទី ១	ជាសហប្រធាន
២_នាយករដ្ឋមន្ត្រីទី២	ជាសហប្រធាន
៣_ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់	ជាអនុប្រធាន
៤_រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង	ជាសមាជិក
៥_រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬតំណាង	សមាជិក
៦_រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង	សមាជិក
៧_រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឬតំណាង	សមាជិក
៨_រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង	សមាជិក
៩_រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន ឬតំណាង	សមាជិក
១០_រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង	សមាជិក
១១_អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬតំណាង	សមាជិក
១២_អភិបាលខេត្តសៀមរាប ឬតំណាង	សមាជិក
១៣_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប	សមាជិក

មាត្រា ២ : ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ អាចអញ្ជើញរដ្ឋមន្ត្រី តំណាងសភាជាតិ តំណាងស្ថាប័នជាតិ និង អន្តរជាតិ ដែលមានការពាក់ព័ន្ធទៅនឹងការងារវប្បធម៌ជាតិអោយចូលមករួមពិភាក្សាតាមករណីចាំបាច់ ។

មាត្រា ៣ : ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ មានភារកិច្ចដូចតទៅ ÷

ក_ពិនិត្យបញ្ចូលជាបេតិកភណ្ឌវប្បធម៌ជាតិ ក្នុងនោះមានតំបន់របណីយដ្ឋាន និង ប្រាសាទជាប្រវត្តិសាស្ត្រ ។

ខ_ការពាររាល់សម្បត្តិវប្បធម៌បុរាណ និង ប្រវត្តិសាស្ត្រមានលក្ខណៈជារូបិយ ។

គ_គ្រប់គ្រង និងត្រួតពិនិត្យតំបន់ប្រាសាទដែលបានកំណត់ទុក និងវត្ថុសិល្បៈមាននៅទីនោះ ។

ឃ_ផ្តល់ការអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យា ការថែរក្សានិងធ្វើអន្តរាគមន៍ដទៃណាដែលពាក់ព័ន្ធ ដល់រាល់តំបន់ប្រាសាទ និង សម្បត្តិវប្បធម៌ជាតិ ។

ង_គ្រប់គ្រងដល់តំបន់ជាប្រវត្តិសាស្ត្រនេះ ដើម្បីការពារបេតិកភណ្ឌជាតិត្រូវ ÷

- រៀបចំនយោបាយលើកតំលៃបេតិកភណ្ឌ
- រៀបចំទូលាយជូនសាធារណៈជនទស្សនា
- រៀបចំក្រុមខ័ណ្ឌទទួលបន្ទុកការងារនេះ
- រៀបចំប្រព័ន្ធទេសចរណ៍

ច_ផ្សព្វផ្សាយតំលៃវប្បធម៌ ស្វែងរកមូលនិធិ បង្រៀនប្រជារាស្ត្រ ហ្វឹកហ្វឺន និងធ្វើការស្រាវជ្រាវពាក់ព័ន្ធបេតិកភណ្ឌជាតិ និង ប្រវត្តិសាស្ត្រជាតិដែលមានភាពជារូបិយ ។

ឆ_ធានាការទទួលខុសត្រូវ និង ករណីយកិច្ចគ្រប់គ្រងជាមួយកិច្ចព្រមព្រៀងផ្នែកវប្បធម៌ និង បណ្តាឥន្ទងទាំងឡាយដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា ។

ជ_ចាត់វិធានការចាំបាច់ ដើម្បីអនុវត្តអោយបានល្អ ការគ្រប់គ្រងគំរោង និង ការងារពាក់ព័ន្ធទៅនឹងការពារថែរក្សា ស្តារ និងលើកតំលៃបេតិកភណ្ឌជាតិ ។

មាត្រា ៤ : សមាជិកទាំងអស់នៃក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវចូលរួមធ្វើការងារតាមសេចក្តីអញ្ជើញ និង ការណែនាំរបស់សហប្រធាន ។

មាត្រា ៥ : សហប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវរៀបចំលេខាធិការដ្ឋានមួយជាអចិន្ត្រៃយ៍ដែលមានទីតាំងនៅ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ៦ : ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

មាត្រា ៧ : បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ ផ្នែកវប្បធម៌ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៨ ៖ នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេច ព្រះរាជក្រឹត្យនេះ ។

មាត្រា ៩ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

***

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យលេខ នស/រកត/០២.៩៥/១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋ មន្ត្រីទី ២ នៃរាជរដ្ឋាភិបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជាកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣ នៃរាជរដ្ឋាភិបាលបណ្តោះ អាសន្នកម្ពុជាស្តីអំពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ តំបន់ និងការ គ្រប់គ្រងតំបន់សៀមរាបអង្គរ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ និងដោយគណៈរដ្ឋមន្ត្រីបានយល់ព្រមផង តាមរយៈការប្រជុំពេញអង្គថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥ ។

ព្រះរាជក្រឹត្យ

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : ត្រូវបានបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ "អប្សរា" ដែលជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្តិ មានស្វ័យភាពរដ្ឋបាល និង ហិរញ្ញវត្ថុ ។

មាត្រា ២ : អាជ្ញាធរ " អប្សរា " មានបេសកកម្មគិតគូរ ដឹកនាំការងាររៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍នៃតំបន់ចំនួនប្រាំ ដែល កំណត់នៅក្នុងព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការកំណត់ និង ការចាត់ចែងតំបន់សៀមរាបអង្គរ ។

ដើម្បីសំរេចទិសដៅនេះ អាជ្ញាធរ " អប្សរា " ព្រមជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួម លើគ្រឹះស្ថានទាំងឡាយដែលមានភារកិច្ចទទួលខុសត្រូវ ក្នុងការគ្រប់គ្រងរមណីយដ្ឋានទាំងនោះ សរុបមាន÷

-អភិរក្សដ្ឋានអង្គរ ដែលមានបេសកកម្មថែរក្សា រៀបចំ និងជួសជុលរមណីយដ្ឋានអង្គរ ដោយធ្វើសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

-ភ្នាក់ងាររៀបចំការអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដែលទទួលបន្ទុកអភិវឌ្ឍន៍ និងសំរបសំរួលបណ្តាញទេសចរណ៍ក្នុង តំបន់នេះ ដោយធ្វើសហការជាមួយក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងជាមួយអនុគណៈកម្មាធិការខេត្ត រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ។

-ភ្នាក់ងារអភិវឌ្ឍន៍នគរូបនីយកម្មទទួលបន្ទុកគិតគូរ និងធ្វើអោយបានសំរេចនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង ឧបរិរចនាសម្ព័ន្ធផ្នែកទេសចរណ៍ក្នុងតំបន់នេះ ក្រោមការក្តោបក្តាប់ផ្ទាល់

របស់អាជ្ញាធរ " អប្សរា " សហការជាមួយអភិបាលខេត្ត សៀមរាប និង អនុគណៈកម្មាធិការខេត្ត រៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ ។

-វិទ្យាស្ថានវប្បធម៌ខ្មែរដែលទទួលបន្ទុកបណ្តុះបណ្តាលប្រវត្តិវិទូ បូរាណវត្ថុវិទូនិងភ្នាក់ងារអភិរក្សទទួលបន្ទុកគ្រប់គ្រង និងទ្រទ្រង់របណីយដ្ឋានអង្គរ ហើយនិងរំាប់រងបង្កើនចំណេះដឹងទាំងឡាយនៅក្នុងផ្នែកវប្បធម៌ និងអរិយធម៌ខ្មែរ ដោយសហការជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ស្នងការពិសេសការពារបេតិកភ័ណ្ឌនៃក្រសួងមហាផ្ទៃ អនុវត្តភារកិច្ចរបស់ខ្លួនក្នុងតំបន់អង្គរដោយសហការជាមួយអាជ្ញាធរខេត្ត សៀមរាប ។

បណ្តាគ្រឹះស្ថានខាងលើនេះ និងត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

មាត្រា៣ : ដើម្បីសំរេចនូវបេសកកម្មរបស់ខ្លួន អាជ្ញាធរ " អប្សរា " ត្រូវកំណត់អោយមានសៀវភៅបន្ទុកសំរាប់អង្គការនានាដែលពាក់ព័ន្ធដល់ការគ្រប់គ្រងរបណីយដ្ឋាន និងការរៀបចំតំបន់អង្គរ ។ ក្នុងន័យនេះ អាជ្ញាធរ " អប្សរា " អាច ៖

-ចុះកិច្ចសន្យាអំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការទាំងនោះ ។

-ចុះកិច្ចសន្យាជាមួយអាជ្ញាធរខេត្តដែលមានបំណងធ្វើការរៀបចំនគរោបនីយកម្មការអភិវឌ្ឍន៍ជនបទ និងការផ្តល់សេវាផ្សេងៗជាយថាហេតុ ។

-សហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗគ្រប់មូលនិធិ និងសមាគមខ្មែរ បរទេសនិងអន្តរជាតិដែលដើរតាមទិសដៅ ឆ្លើយតបនឹងសមត្ថកិច្ចអាជ្ញាធរ " អប្សរា " ។

-សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងរឿងវិនិយោគគ្រប់ប្រភេទណា ដែលមានការពាក់ព័ន្ធជាមួយបេសកកម្មរបស់អាជ្ញាធរ " អប្សរា " ។

-ប្រគល់សិទ្ធិធ្វើសកម្មភាពផ្សេងៗឬចេញច្បាប់អនុញ្ញាតកាន់កាប់ ផ្តល់ការជួលដីរដ្ឋអោយអ្នកវិនិយោគ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់អាជ្ញាធរ " អប្សរា " ។

អាស្រ័យតាមកំរិតនៃការរីកចំរើននូវសកម្មភាពរបស់ខ្លួន អាជ្ញាធរ " អប្សរា " អាចប្រគល់សិទ្ធិទាំងស្រុង ឬមួយភាគដែលរៀបរាប់ខាងលើនេះ ជូនដល់គ្រឹះស្ថានដែលមានចែងក្នុងមាត្រា ២ ។

ក្នុងរយៈពេលរង់ចាំការបង្កើតគ្រឹះស្ថានទាំងឡាយដូចបានព្រាងទុកក្នុងមាត្រា ២ ខាងលើ អាជ្ញាធរ " អប្សរា " ទទួល រ៉ាប់រងរាល់បេសកកម្មដែលជាសមត្ថកិច្ចរបស់គ្រឹះស្ថាននោះ ។

មាត្រា ៤ : អាជ្ញាធរ " អប្សរា " ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីនយោបាយសកម្មភាពរបស់ខ្លួន ការវិនិយោគ និង សេចក្តីអនុញ្ញាតផ្សេងៗដែលត្រូវបានសំរេចហើយ ។

ជំពូកទី ២

រដ្ឋបាល

មាត្រា ៥ : អាជ្ញាធរ " អប្សរា " ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាព ÷

- នាយករដ្ឋមន្ត្រីទី ១ ជាសហប្រធាន
- នាយករដ្ឋមន្ត្រីទី ២ ជាសហប្រធាន
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឬតំណាង ជាអនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង សមាជិក
- អគ្គលេខាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬតំណាង សមាជិក
- អភិបាលខេត្តសៀមរាប ឬតំណាង សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប ឬតំណាង សមាជិក

មាត្រា ៦ : ក្រុមប្រឹក្សាភិបាលមានសិទ្ធិអនុម័ត ÷

-ការតំរង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរ " អប្សរា "

-បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរ " អប្សរា "

-របាយការណ៍ប្រចាំឆ្នាំដែលអគ្គនាយកបានដាក់ជូន

- ចំនួនទឹកប្រាក់ និងថ្លៃឈ្នួលផ្សេងៗនិងចំណូលគ្រប់បែបដែលអាជ្ញាធរ " អប្សរា " ប្រមូលទារបាន

-ចំនួនទឹកប្រាក់ហើយនិងលក្ខខ័ណ្ឌនៃការខ្ចីបុល

-រាល់បញ្ហាដែលសហប្រធាន និង អគ្គនាយកដាក់អោយពិនិត្យ ។

មាត្រា ៧ : ក្រុមប្រឹក្សាភិបាលប្រជុំយ៉ាងតិច ៦ ដងក្នុងមួយឆ្នាំ តាមការកោះអញ្ជើញរបស់សហប្រធានដែលជាអ្នកកំណត់របៀបវារៈ ។ ក្រុមប្រឹក្សាភិបាលត្រូវប្រជុំក្នុងខែបន្ទាប់ បើសិនជាការកោះអញ្ជើញត្រូវបានសុំដោយសមាជិកចំនួន ១ ភាគ ៤ នៃសមាជិកទាំងអស់ ។ ការអនុម័តផ្សេងៗ ត្រូវកំណត់យកតាមសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ ក្នុងករណីមានចំណែកសំលេងស្មើគ្នាសំលេងសហប្រធានមានឧត្តមានុភាព ។

សហប្រធានអាចអញ្ជើញរាល់បុគ្គលណាក៏ដោយ អោយមកចូលរួមបានក្នុងអង្គប្រជុំ ក្នុងករណីដែលខ្លួនយល់ថាវត្តមានបុគ្គលនោះមានផលប្រយោជន៍ ។

មាត្រា ៨ : អាជ្ញាធរ " អប្សរា " មានទីចាត់ការទូទៅ និងនាយកដ្ឋានជំនាញចំនួន ៣ ទៀតគឺ នាយកដ្ឋានសកម្មភាពភូមិបាល នាយកដ្ឋាននគរោបនីយកម្ម និងនាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ ។ ទីចាត់ការទូទៅដឹកនាំដោយអគ្គនាយកមួយរូប និងមានអ្នកជំនួយការជាទីប្រឹក្សា មួយរូបផ្នែកខាងរៀបចំផែនការ ហើយនិងការងារចាត់តាំង ។

នាយកដ្ឋានកិច្ចការភូមិបាលមានតួនាទីត្រួតពិនិត្យសកម្មភាពភូមិបាល ។ នាយកដ្ឋាននេះដឹកនាំដោយអ្នកឯកទេសខាង ភូមិបាលមួយរូប ។

នាយកដ្ឋានកិច្ចការនគរោបនីយកម្ម (នា.ក.ន) មានភារកិច្ច ÷

-ទទួលខុសត្រូវក្នុងការបន្តកិច្ចការ និង ការអនុវត្តន៍ជាក់ស្តែងនូវគំរោងអភិវឌ្ឍន៍ទាំងឡាយក្នុងតំបន់ ។

-ទទួលខុសត្រូវការសិក្សាស្រាវជ្រាវផ្នែកនគរូបនីយកម្ម ដើម្បីអោយមានការអនុវត្តន៍ព្រមទាំងគោរពរាល់បញ្ញត្តិក្នុង កិច្ចការទាំងនោះ ។ នា.ក.ន ដឹកនាំដោយស្ថាបត្យករនគររូបនីយកម្មមួយរូប ។

-នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យទទួលខុសត្រូវកិច្ចការកាន់កាប់គណនេយ្យរបស់អាជ្ញាធរ " អប្សរា " ។ នាយកដ្ឋាននេះជាជំនួយការដល់អគ្គនាយក ក្នុងកិច្ចការត្រួតពិនិត្យអោយបានត្រឹមត្រូវនូវរាល់សកម្មភាពពាក់ព័ន្ធកិច្ចសន្យា ការងារវិនិយោគឬការអនុញ្ញាត ។

នាយកដ្ឋាននេះដឹកនាំដោយនាយកហិរញ្ញកិច្ច និងគណនេយ្យមួយរូប ដែលអាចចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សា ភិបាល ដោយមានសំលេងត្រឹមតែជាការផ្តល់យោបល់ ។

មាត្រា ៩ : អគ្គនាយកនៃអាជ្ញាធរ " អប្សរា " ត្រូវតែងតាំងដោយអនុក្រឹត្យ តាមការស្នើរបស់ក្រុមប្រឹក្សាភិបាលសំរាប់ រយៈពេល ៣ ឆ្នាំ រួចអាចបន្ត ៣ ឆ្នាំម្តងៗទៀតបាន ។ អគ្គនាយកជាអាណាប័កក្នុងការចំណាយរបស់អាជ្ញាធរ " អប្សរា " ។អគ្គនាយកទទួលរ៉ាប់រងអនុវត្ត រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ហើយនិងចាត់វិធានការគ្រប់គ្រង គ្រប់បែបយ៉ាងក្នុងដំណើរការរបស់អាជ្ញាធរ " អប្សរា " ។ អគ្គនាយកទទួលរ៉ាប់រងអនុវត្ត រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ហើយនិងចាត់វិធានការគ្រប់គ្រង គ្រប់បែបយ៉ាងក្នុងដំណើរការរបស់អាជ្ញាធរ " អប្សរា " ។ អគ្គនាយកតំណាង អោយអាជ្ញាធរ " អប្សរា " នៅចំពោះមុខតុលាការ ។ អគ្គនាយកតែងតាំង និងតំលើងឋានន្តរសក្តិបុគ្គលិក បន្ទាប់ពីបានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។ អគ្គនាយកមានអំណាចពេញទីលើបុគ្គលិកអាជ្ញាធរ " អប្សរា " លើកលែងតែនាយកហិរញ្ញកិច្ច និងគណនេយ្យ ។

មាត្រា ១០ : បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ " អប្សរា " ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៣
វិសមិតភាព

មាត្រា ១១ : អគ្គនាយក នាយកហិរញ្ញកិច្ច និងគណនេយ្យ សមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរ "អប្សរា " ពុំអាចទទួលផលប្រយោជន៍អ្វីដោយផ្ទាល់ក្តី ឬតាមរយៈស្វាមី ឬភរិយា ឬកូនរបស់ខ្លួន នៅក្នុងសហគ្រាសឯកជនណាមួយ ដែលធ្វើអាជីវកម្មក្រោមសមត្ថកិច្ចអាជ្ញាធរ " អប្សរា " ។ ក្នុង

រករណីមិនគោរពកាតព្វកិច្ចនេះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើ កំណត់ហេតុ ស្តីពីវិសមិតភាពការងាររបស់សាមីជន ហើយប្រកាសអោយលាលែងពីមុខតំណែងតែម្តង ។

ជំពូកទី ៤

ប្រភពធនធាន

មាត្រា ១២ ធនធានរបស់អាជ្ញាធរ " អប្សរា " មាន ÷

- វិភាគទានពីរដ្ឋ និងពីឃុំ ស្រុក ខេត្ត នានា
- អំណោយមរតក និងវិភាគទានអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ " អប្សរា " ។
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរ " អប្សរា " ដូចជាចំណុលថ្លៃឈ្នួលបានមកពីការចេញច្បាប់ កាន់កាប់ផ្សេងៗ ។
- ប្រាក់កំរៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្តល់មកពីអង្គការសាធារណៈ ឬឯកជន ។
- ប្រាក់ខ្ចីបុលដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" ។ អាជ្ញាធរ " អប្សរា " អាចទទួលយកនូវទ្រព្យចលនវត្ថុ អចលនវត្ថុឬដីធ្លី ដែលគេប្រគល់អោយ ។

មាត្រា ១៣ : គំរោងចំណូល និងចំណាយ សំរាប់ឆ្នាំបន្ទាប់ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុតនៅថ្ងៃទី ០១ ខែ ធ្នូ ។

ជំពូកទី ៥

ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការត្រួតពិនិត្យគណនេយ្យ

មាត្រា ១៤ : ការគ្រប់គ្រងហិរញ្ញវត្ថុនៃអាជ្ញាធរ " អប្សរា " ជាភារកិច្ចរបស់នាយកហិរញ្ញកិច្ច និង គណនេយ្យ ១ រូប ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីរូបនេះដែលជាអ្នកទទួលខុសត្រូវក្នុងការ គ្រប់គ្រងមូលនិធិនេះ ព្រមទាំងជាអ្នកកាន់កាប់បញ្ជីសារពើភណ្ឌបេតិកភ័ណ្ឌរបស់អាជ្ញាធរ " អប្សរា " ត្រូវធ្វើសច្ចាប្រណិធានមុន នឹងចូលកាន់តំណែង ។

មាត្រា ១៥ : ការត្រួតពិនិត្យគណនេយ្យ ត្រូវប្រគល់អោយស្នងការគណនេយ្យ ១ រូប ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ស្នងការគណនេយ្យទទួលអំណាចក្នុងផ្ទាត់ផ្ទៀងបេឡា ត្រួតពិនិត្យភាពប្រក្រតីនៃតុល្យការ ផ្សេងៗព្រមទាំងភាពត្រឹមត្រូវនៃគណនេយ្យ ។

ស្នងការគណនេយ្យអាចធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យរាល់ពេលដែលខ្លួនយល់ថាចាំបាច់ ។ រាល់ពេលប្រជុំក្រុមប្រឹក្សាភិបាល ស្នងការគណនេយ្យធ្វើរបាយការណ៍អំពីការដែលខ្លួនបានធ្វើកន្លងមក ។ ប្រសិនបើខ្លួនសង្កេតឃើញភាពមិនប្រក្រតី និងមិនទៀងទាត់ ស្នងការគណនេយ្យ ត្រូវជំរាបអង្គប្រជុំព្រមទាំងបញ្ចេញយោបល់លើស្ថានភាពហិរញ្ញវត្ថុនោះ ។

_បើមានករណីបន្ទាន់ស្នងការ គណនេយ្យអាចសុំសហប្រធានក្រុមប្រឹក្សាភិបាលអោយកោះអញ្ជើញប្រជុំក្រុមប្រឹក្សាភិបាល ។ ស្នងការគណនេយ្យមានសិទ្ធិទទួលកប្រៃក្នុងកំរិតដែលក្រុមប្រឹក្សាភិបាលបានកំណត់ ។ ក្រោយពីបានត្រួតពិនិត្យគណនេយ្យប្រចាំឆ្នាំរួចហើយ បើស្នងការគណនេយ្យពុំឃើញមានភាពមិនប្រក្រតី ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុទេនោះស្នងការគណនេយ្យត្រូវប្រគល់បុព្វនកិច្ចដល់ក្រុមប្រឹក្សាភិបាល អគ្គនាយក និង នាយកហិរញ្ញកិច្ចគណនេយ្យនៃអាជ្ញាធរ " អប្សរា " ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ១៦ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧ នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ និងអភិបាលខេត្ត សៀមរាប ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ១៨ ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីពេលឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦
ស្តីអំពីការបង្កើតមជ្ឈមណ្ឌល
សកម្មភាពកំចាត់មីនកម្ពុជា

យើង
ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានទ្រង់យល់ព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានទ្រង់យល់សេចក្តីអនុម័តទុកចិត្តរបស់រដ្ឋសភា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ លើសំណើររបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានទ្រង់យល់ព្រះរាជក្រឹត្យស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ។
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសកម្មភាពមីន កម្ពុជា
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

ក្រាស់បន្ទាប់

ជំពូកទី ១

នីតិសារជាតិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

មាត្រា ១ : បានត្រូវបង្កើតឡើង នូវមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ថា ម.ស.ម.ក ។ ម.ស.ម.ក ជាគ្រឹះស្ថានសាធារណៈប្រកបដោយបុគ្គលភាពគតិយុត្តិ ដែលស្ថិតនៅក្រោមអាណាព្យាបាលនៃនាយករដ្ឋមន្ត្រី ។ ម.ស.ម.ក មានសិទ្ធិដើម្បី :

ក_ចុះកិច្ចសន្យា ឬ បំពេញកាតព្វកិច្ចផ្សេងទៀត ដើម្បីធ្វើអោយសំរេចបេសកកម្មរបស់ខ្លួន ។

ខ_ជ្រើសរើស និង ប្រើប្រាស់បុគ្គលិកទាំងឡាយ ដែលចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

មាត្រា ២ : ម.ស.ម.ក មិនត្រូវធ្វើសកម្មភាពពាណិជ្ជកម្មណាមួយឡើយ ។

ជំពូកទី ២

គោលដៅ និង សកម្មភាព

មាត្រា ៣ : ម.ស.ម.ក ត្រូវមានភារកិច្ចធ្វើការសំរបសំរួលរាល់សកម្មភាពកំចាត់មីនទាំងអស់ ។

មាត្រា ៤ : ម.ស.ម.ក អាចចែករំលែកបច្ចេកទេស និង ការពិសោធន៍របស់ខ្លួនទៅអោយប្រទេសទាំងឡាយណាដែលមានបញ្ហាមីន ។

មាត្រា ៥ : ម.ស.ម.ក ត្រូវកំណត់អោយបានច្បាស់ និង អនុវត្តកម្មវិធីដូចតទៅ :

ក_ការយល់ដឹងអំពីគ្រោះថ្នាក់មីន ។

ខ_ពត៌មានអំពីចំការមីន និង ការដាក់ផ្លាកសញ្ញាមីន ។

គ_ការបោសសំអាតមីន រួមបញ្ចូលទាំងការកំទេចគ្រឿងផ្ទុះចោល ។

ឃ_ការហ្វឹកហ្វឺនក្នុងការសំអាតមីន ។

ម.ស.ម.ក ត្រូវចាត់វិធានការផ្តល់សុវត្ថិភាពអោយបានកំរិតខ្ពស់បំផុត ដល់បុគ្គលិកទាំងអស់របស់ខ្លួន ។

មាត្រា ៦ : កម្មវិធីខាងលើត្រូវអនុវត្តក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ និងត្រូវប្រព្រឹត្តទៅតាមលំដាប់អាទិភាពដូចតទៅ :

ក_តាមផ្លូវមនុស្សធម៌ ដើម្បីជួយជនភៀសខ្លួនដែលមកតាំងទីលំនៅថ្មី និងជួយដល់ការចាប់ជីវិតទៅប្រភេទផ្សេងៗទៀត ។

ខ_តាមផ្លូវសេដ្ឋកិច្ច ដើម្បីជួយពង្រីកកសិកម្ម និង ដើម្បីជួយស្តារ ឬ កសាងជាតិឡើងវិញ ឬតាមគំរោងការអភិវឌ្ឍន៍ ។

គ_តាមផ្លូវផ្សេងៗទៀត

ជំពូកទី ៣
ការគ្រប់គ្រងមជ្ឈមណ្ឌល

មាត្រា ៧ : ម.ស.ម.ក ត្រូវមាន:

ក_ក្រុមប្រឹក្សាភិបាល មួយ

ខ_នាយកម្នាក់

គ_ហិរញ្ញិកម្នាក់

ឃ_អង្គភាពរដ្ឋបាល និង បច្ចេកទេស

ជំពូកទី ៤
ក្រុមប្រឹក្សាភិបាល

មាត្រា ៨ : ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកពី ៩ ទៅ ១២ នាក់ដែលអាចមានសមាជិកអន្តរជាតិនៅក្នុងចំណោមនោះផង ។ សមាជិកជាតិត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

មាត្រា ៩ : ក្រុមប្រឹក្សាភិបាលត្រូវមានប្រធាន ១ នាក់ អនុប្រធាន ១ នាក់ ហើយនិងលេខាធិការ ១ នាក់ ។ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជាស្វ័យប្រវត្តិ ជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីដែលនាយរដ្ឋមន្ត្រីមិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រីអាចស្នើថ្វាយព្រះមហាក្សត្រ ដើម្បីតែងតាំងតំណាងម្នាក់ជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលត្រូវបោះឆ្នោតជ្រើសរើសអនុប្រធានរបស់ខ្លួន។

មាត្រា ១០ : សមាជិកខ្មែរដទៃទៀតនៃក្រុមប្រឹក្សាភិបាល ជាតំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ តំណាងរដ្ឋមន្ត្រីក្រសួងការបរទេស ក្រៅពីនេះជា

វៈជនសំខាន់ៗទៀត ។ សមាជិកអន្តរជាតិអាចតែងតាំងដោយនាយករដ្ឋមន្ត្រី ក្នុងករណីមានការស្នើសុំពីប្រទេសផ្តល់ជំនួយ ។

មាត្រា ១១ ៖ សមាជិកម្នាក់ត្រូវជាអ្នកតំណាងអង្គការក្រៅរដ្ឋាភិបាលខ្មែរទាំងឡាយ ។

មាត្រា ១២ ៖ នាយកនៃ ម.ស.ម.ក ត្រូវបានចាត់តាំងជាសមាជិកនិងជាលេខាធិការនៃក្រុមប្រឹក្សាភិបាល ។

មាត្រា ១៣ ៖ ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុអាចចូលរួមក្នុងក្រុមប្រឹក្សាភិបាលបានក្នុងឋានៈជាអ្នកសង្កេតការណ៍ដែលមិនត្រូវមានចំនួនលើសពីពីរនាក់ទេ ។

មាត្រា ១៤ ៖ ប្រទេសផ្តល់ជំនួយអាចចូលរួមក្នុងក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

មាត្រា ១៥ ៖ ក្រុមប្រឹក្សាភិបាលត្រូវមានអាណត្តិចំនួនបីឆ្នាំ ហើយសមាជិកនៃក្រុមប្រឹក្សាភិបាលនេះអាចត្រូវបានតែងតាំងជាថ្មីទៀត ។ សមាជិកភាពនៃតំណាងអចិន្ត្រៃយ៍របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងហិរញ្ញវត្ថុ និង ក្រសួងការបរទេសគ្មានកំណត់អាណត្តិឡើយ ។

មាត្រា ១៦ ៖ ក្រុមប្រឹក្សាភិបាលត្រូវបើកកិច្ចប្រជុំសាមញ្ញមួយដងក្នុងមួយត្រីមាស ហើយនិងកិច្ចប្រជុំប្រចាំឆ្នាំមួយ នៅដំណាច់ឆ្នាំហិរញ្ញវត្ថុ ។ ប្រធាន អនុប្រធាន ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាភិបាលអាចកោះកិច្ចប្រជុំវិសាមញ្ញបាន។

មាត្រា ១៧ ៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនឹងយកជាការបាន លុះត្រាតែមានសមាជិកភាគច្រើនដាច់ខាតចូលរួម ។ នៅពេលដែលមានសមាជិកខ្មែរផង និង សមាជិកអន្តរជាតិផង ក្នុងចំណោមចំនួនដ៏តិចបំផុតសំរាប់ប្រជុំនេះ អង្គប្រជុំត្រូវមានសមាជិកអន្តរជាតិយ៉ាងហោចក៏មួយនាក់ដែរទើយយកជាការបាន ។ ក្រោយដែលមិនបានសមាជិកភាគច្រើន ចូលរួមគេត្រូវអញ្ជើញសមាជិកទាំងអស់ម្តងទៀតបើកប្រជុំហើយសមាជិកដែលមានវត្តមានក្រោយការជំរាបអញ្ជើញនេះ នឹងយកជាបានការដើម្បីធ្វើកិច្ចប្រជុំ ។

មាត្រា ១៨ ៖ សមាជិកអាចចាត់អ្នកតំណាងរបស់ខ្លួនអោយចូលរួមប្រជុំក្រុមប្រឹក្សាភិបាល ។ សមាជិកម្នាក់ៗ ឬអ្នកតំណាងរបស់ខ្លួនត្រូវមានសិទ្ធិមានឆ្នោតតែមួយគត់ ។ សេចក្តីសំរេចនឹងយកជាការបានបើមានសមាជិកភាគច្រើនបោះឆ្នោតគាំទ្រ និង សន្លឹកឆ្នោតប្រឆាំង ប្រធានត្រូវធ្វើសេចក្តីសំរេចជាចុងក្រោយ ។

មាត្រា ១៩ ៖ ក្រុមប្រឹក្សាភិបាលត្រូវមានមុខងារដូចតទៅ៖

ក_តាមពិនិត្យមើលសកម្មភាព ម.ស.ម.ក ហើយនិងផ្តល់ការណែនាំដើម្បីធ្វើអោយកិច្ចប្រតិបត្តិការប្រព្រឹត្តទៅ ស្របនិងគោលដៅហើយនិងសកម្មភាពរបស់មជ្ឈមណ្ឌលដែលមានចែងក្នុងជំពូកទី ២ ស្រាប់

ខ_អនុម័តយល់ព្រមលើកម្មវិធី ផែនការការងារ ថវិកា គណនេយ្យហើយនិងរបាយការណ៍របស់ ម.ស.ម.ក ។

គ_អនុម័តយល់ព្រមលើបទបញ្ញាផ្ទៃក្នុងទាំងឡាយរបស់ ម.ស.ម.ក ស្តីអំពីការរៀបចំអង្គការ អំពីហិរញ្ញវត្ថុ និង អំពីបុគ្គលិក ។

ឃ_សំរេចលើបញ្ហាទាំងឡាយដែលទាក់ទងនិង ម.ស.ម.ក ។

មាត្រា ២០ : សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនិងចូលជាធរមានប្រាំពីរថ្ងៃក្រោយដែលបានអនុម័តរួច ។

ជំពូកទី ៥

នាយក

មាត្រា ២១ : នាយកត្រូវបានតែងតាំងឡើង ដោយព្រះរាជក្រឹត្យសំរាប់អាណត្តិ បីឆ្នាំ ដោយមានការស្នើពីសំណាក់ក្រុមប្រឹក្សាភិបាលទៅគណៈរដ្ឋមន្ត្រី ។ការតែងតាំងនេះអាចធ្វើឡើងវិញជាថ្មីបាន ។

មាត្រា ២២ : នាយកអាចស្នើការជ្រើសរើសនាយករងទី ១ នាក់ទៅក្រុមប្រឹក្សាភិបាល ។ នាយករងនេះត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ។

មាត្រា ២៣ : នាយកត្រូវមានមុខនាទីជាអ្នកដឹកនាំចាត់ចែងទូទៅនៃ ម.ស.ម.ក ហើយជាអ្នកតំណាងមជ្ឈមណ្ឌលនេះ ។

មាត្រា ២៤ : នាយកត្រូវមានមុខការជាអាទិ៍ដូចតទៅ :

ក_រៀបចំចាត់ចែង និង គ្រប់គ្រង ម.ស.ម.ក ទៅតាមលក្ខន្តិកៈនេះ ។

ខ_អនុវត្តតាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

គ_ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយល់ព្រមនូវកម្មវិធី ផែនការការងារគំរោងថវិកា គណនេយ្យ ហើយនិងរបាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.អ.ក ។

ឃ_ដាក់ជូនក្រសួងហិរញ្ញវត្ថុ ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ហើយនិងប្រទេសផ្តល់ជំនួយឧបត្ថម្ភ គណនេយ្យ និង របាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.ម.ក ។

ង_ដឹកនាំកម្មវិធីការងារ ម.ស.ម.កហើយនិងអនុញ្ញាតចំណាយដែលមានចែងក្នុងថវិកា ។

ច_តែងតាំង ដឹកនាំបុគ្គលិក និង តំលើងឋានន្តរសក្តិរបស់បុគ្គលិក នៃ ម.ស.ម.ក ហើយនិង ដាក់វិន័យទៅតាមបទបញ្ជាដែលក្រុមប្រឹក្សាភិបាលបានសំរេចយល់ព្រមហើយដើម្បី លើកកំពស់ប្រសិទ្ធភាពសមត្ថភាព និងការស្អាតស្អំ ក្នុងការធ្វើការងារអោយបាន កំរិតខ្ពស់ជាទីបំផុត ។

ឆ_ទទួលបន្ទុកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាល ។

មាត្រា ២៥ : ក្នុងការបំពេញភារកិច្ចទាំងឡាយនេះ នាយកអាចមានជំនួយពីទីប្រឹក្សាបច្ចេកទេសមួយចំនួន ។

មាត្រា ២៦ : នាយកអាចផ្ទេរអំណាចរបស់ខ្លួនទៅបុគ្គលិកក្រោមបង្គាប់ ។ នាយកអាចចែករំលែកអំណាចក្នុង ការចាត់ចែងហិរញ្ញវត្ថុនៃ ម.ស.ម.ក ទៅអោយហិរញ្ញិក ។

ជំពូកទី ៦
ហិរញ្ញិក

មាត្រា ២៧ : ម.ស.ម.ក ត្រូវមានហិរញ្ញិកមួយនាក់ ។ នាយកត្រូវស្នើការតែងតាំងហិរញ្ញិកនេះទៅក្រុមប្រឹក្សា ភិបាលដើម្បីសុំការអនុម័តយល់ព្រមជាស្ថាពរ ។ ហិរញ្ញិកអាចជាបុគ្គលិកខ្មែរ ឬជាបុគ្គលិកអន្តជាតិ ។ ភ្នាក់ងារផ្តល់ជំនួយធំអាចស្នើការតែងតាំងហិរញ្ញិកនេះបាន ។

មាត្រា ២៨ : ហិរញ្ញិកត្រូវមានមុខងារជាអាទិ៍ដូចតទៅ :

ក_ជួយរៀបចំកិច្ចព្រមព្រៀងអំពីគំរោងការរវាង ម.ស.ម.ក និងភ្នាក់ងារផ្តល់ជំនួយ ។

ខ_បំពេញមុខការចាំបាច់ទាំងឡាយខាងហិរញ្ញវត្ថុ និង ខាងគណនេយ្យសំរាប់ម.ស.ម.ក រាប់បញ្ចូលទាំងការថែ រក្សាមូលនិធិរបស់មជ្ឈមណ្ឌលរួមគ្នាជាមួយនិងនាយក ។

គ_ជួយរៀបចំគំរោងការថវិកា ។

ឃ_ជួយរៀបចំច្បាប់ទាំងឡាយខាងផ្នែកហិរញ្ញវត្ថុសំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាល សំរេចអនុម័ត ។

ង_ជួយធ្វើអោយមានការអនុវត្តច្បាប់ខាងលើនេះ ។

ច_បើកប្រាក់ចំណាយដោយមានការអនុញ្ញាតពីនាយក ម.ស.ម.ក ។

ឆ_រៀបចំ និង បញ្ជាក់និយ័តភាពគណនេយ្យប្រចាំឆ្នាំ ។

ជ_ជួយរៀបចំចាត់ចែងកសុភា និងជួយមើលការទិញសំភារៈ ព្រមទាំងចាត់ចែងសំភារៈ បរិក្ខារបស់ ម.ស.ម.ក អោយបានត្រឹមត្រូវ ។

ឈ-ជួយរៀបចំឯកសារទាំងឡាយ ដែលត្រូវដាក់ជូនភ្នាក់ងារផ្តល់ជំនួយ ។

ញ-ជួយសំរួលការត្រួតពិនិត្យ គណនេយ្យរបស់ ម.ស.ម.ក ។

ដ-ធ្វើសេចក្តីរាយការណ៍អំពីចំណូល ចំណាយរៀងរាល់ខែជូនក្រុមប្រឹក្សាភិបាល ។

មាត្រា ២៩ : ហិរញ្ញិកត្រូវបំពេញមុខនាទីជានាយគណនេយ្យនៃ ម.ស.ម.ក ។

ជំពូកទី ៧
អង្គភាពរដ្ឋបាល និង បច្ចេកទេស

មាត្រា ៣០ : ម.ស.ម.ក ត្រូវមានអង្គភាពរដ្ឋបាល និង បច្ចេកទេសដែលចាំបាច់ក្នុងការបំពេញភារកិច្ច និងដើម្បីអោយបានសំរេចគោលបំណងរបស់ខ្លួន ។ ម.ស.ម.ក ត្រូវមានបុគ្គលិករដ្ឋបាល និងបច្ចេកទេសដែលមាន ការអប់រំហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវ និងគុណសម្បត្តិខ្ពស់ ដើម្បីចាត់ចែងអង្គភាពទាំងនេះ ។ ម.ស.ម.ក ត្រូវជាស្ថាប័នមួយដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពសមត្ថភាព និង ភាពស្អាតស្អំ ។

មាត្រា ៣១ : រចនាសម្ព័ន្ធ និង ការរៀបចំជាអង្គការរបស់ ម.ស.ម.ក ត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ជំពូកទី ៨
ការចាត់ចែងហិរញ្ញវត្ថុ

មាត្រា ៣២ : ម.ស.ម.ក ជាស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានទិសដៅមិនស្វែងរកចំណេញឡើយ ។ ម.ស.ម.ក ត្រូវមានថវិការបស់ខ្លួន សំរាប់ការរៀបចំប្រព្រឹត្តទៅ និង សំរាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់ខ្លួន ។

មាត្រា ៣៣ : ម.ស.ម.ក អាចសុំ អាចទទួល អាចទិញ ឬពុំនោះទេ អាចសុំពីស្ថាប័នរដ្ឋាភិបាល ឬអន្តររដ្ឋាភិបាល ឬពីបុគ្គល ឬក៏ពីក្រុមហ៊ុន ឬក៏ពីស្ថាប័នឯទៀតៗ ដោយអំណោយក្តី ឬក៏ដោយមធ្យោបាយឯទៀតណាក៏ដោយក្តី នូវធនធានទាំងឡាយរាប់ទាំងប្រាក់កាស និងអំណោយដែលមានប្រយោជន៍ឬដែលត្រូវការចាំបាច់ក្នុងការធ្វើអោយសំរេចគោលដៅរបស់ខ្លួន ។ ម.ស.ម.ក អាច រក្សាទុក អាចជាម្ចាស់ អាចគ្រប់គ្រង អាចប្រើប្រាស់ អាចផ្ទេរបន្តឬក៏អាចលក់ចេញ ឬក៏ផ្តល់អោយអ្នកដទៃនូវធនធានខាងលើនេះ ។ ម.ស.ម.កអាចទិញចលនៈ ឬអចលនៈវត្ថុណាដែលឃើញថា ចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

មាត្រា ៣៤ : ម.ស.ម.ក អាចសុំ អាចទទួល អាចទិញ ឬពុំនោះទេអាចសុំយកពីស្ថាប័នរដ្ឋាភិបាល ឬ អន្តររដ្ឋាភិបាលឬពីបុគ្គល ឬក៏ពីក្រុមហ៊ុន ឬក៏ពីស្ថាប័នទៀត នូវសិទ្ធិ ការអនុញ្ញាត ការផ្ទេរប្រគល់អោយហើយនិងជំនួយឧបត្ថម្ភទោះជាហិរញ្ញវត្ថុក្តី ឬ ប្រភេទណាផ្សេងទៀតក្តី ដែលជួយសំរួលក្នុងការធ្វើអោយគោលដៅរបស់ខ្លួនបានសំរេច ។

មាត្រា ៣៥ : ម.ស.ម.ក អាចអោយបុគ្គលឯកជន ឬក្រុមហ៊ុន ឬឯកជនផ្សេងៗទៀត បង់ប្រាក់លើផលិតផល ឬសេវាកម្មដែលខ្លួនផ្តល់អោយ ។ ថ្លៃទាំងនេះមិនត្រូវអោយហួសលើសពីតំលៃផលិតកម្មឡើយ ។

មាត្រា ៣៦ : ម.ស.ម.ក ត្រូវមានបែបបទហិរញ្ញវត្ថុរបស់ខ្លួន ហើយត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុ អោយទៀងទាត់ជូនទៅក្រុមប្រឹក្សាភិបាល ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ហើយនឹងប្រទេសផ្តល់ជំនួយ ។

មាត្រា ៣៧ : គណនេយ្យចំណាយចំណូលរបស់ ម.ស.ម.ក ត្រូវបើកចំហរអោយមានការត្រួតពិនិត្យផែកធេរពីសំណាក់អង្គការឯករាជ្យណាមួយ ឬពីសំណាក់ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ឬប្រទេសផ្តល់ជំនួយឧបត្ថម្ភ ។

មាត្រា ៣៨ : ម.ស.ម.ក ត្រូវបានជាម្ចាស់សម្បត្តិទាំងឡាយដែលខ្លួនរកបាន ។

មាត្រា ៣៩ : ម.ស.ម.ក ត្រូវបានរួចពីពន្ធគយ លើទំនិញទាំងឡាយដែលខ្លួនទិញឬក៏ទទួលជាអំណោយសំរាប់ការកកើតនិងប្រព្រឹត្តទៅ ហើយនិងសកម្មភាពរបស់ខ្លួន ។

ជំពូកទី ៩
ការជាប់សំណង និង វិវាទ

មាត្រា ៤០ : បុគ្គលិកនិងសមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក នឹងមិនត្រូវជាប់សំណងផ្ទាល់ខ្លួនប្រភេទណាមួយឡើយដោយការខូចខាត ដល់អ្នកទៀត ដែលបណ្តាលមកពីសកម្មភាពខ្លួននៅពេលបំពេញមុខងារផ្លូវការរបស់ខ្លួន ។

មាត្រា ៤១ : ម.ស.ម.ក ត្រូវទទួលខុសត្រូវចំពោះករណីយតវ៉ាអោយសងសំណងនេះ ទៅតាមច្បាប់ដែលមានជាធរមាន ។

មាត្រា ៤២ : ម.ស.ម.ក ចេញមុខការពារ ឬ ប្តឹងតវ៉ាជំនួសក្នុងករណីដែលមានវិវាទ ។ ម.ស.ម.ក មានភារកិច្ចចេញមុខការពារតវ៉ា ឬ ដោះស្រាយការទាមទារ ឬ បណ្តឹងផ្សេងៗទៀត ដែលបណ្តាលមកពីសកម្មភាព ឬ កិច្ចប្រតិបត្តិការ នៃ ម.ស.ម.ក រាប់ទាំងប្រាក់ចំណាយនៃរឿងវិវាទនោះផង ។

ជំពូកទី ១០
ផុតរលាយ

មាត្រា ៤៣ : ម.ស.ម.ក ត្រូវស្ថិតនៅជាស្ថាប័នមានការប្រព្រឹត្តទៅ រហូតដល់ពេលដែលខ្លួនបានបំពេញបេសកកម្មរបស់ខ្លួនចប់សព្វគ្រប់ហើយ ។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការសំរេចអំពីការចប់បេសកកម្មនេះ ហើយនិងអំពីការចាត់ចែងសម្បត្តិរបស់ ម.ស.ម.ក ដែល នៅសល់ក្រោយពីបានសងបំណុលគេទាំងអស់ ។ ការបញ្ចប់បេសកកម្មនៃ ម.ស.ម.ក ហើយនិងការផ្ទេរសិទ្ធិដែលខ្លួនមានហើយនិងបំណុលរបស់ខ្លួនត្រូវមានការទទួលយល់ព្រមពី រាជរដ្ឋាភិបាល ។

ជំពូកទី ១១
អវសានប្បញ្ញត្តិ

មាត្រា ៤៤ : នៅពេលដែលពុំទាន់មានការតែងតាំងហិរញ្ញិក នាយកត្រូវទទួលបន្ទុកមុខនាទីនេះ នៅចំពោះមុខក្រុមប្រឹក្សាភិបាល។

មាត្រា ៤៥ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៤៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា	ហត្ថលេខា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យ នស/រកត/០២៩៥/១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៥

ក្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក **សាវ៉ាត់ ខាន់** ជាអគ្គនាយកនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ធ្វើនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យ នស/រកត/០២៩៥/១៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ប៉ោ ម៉ិនស្រ៊ី** ជាបេសកជនពិសេស របស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើរដ្ឋមន្ត្រី ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យ នស/រកត/០២៩៥/១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើនៅថ្ងៃទី ២៤.៩.១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា

-តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី

ទ្រង់ត្រាស់សំរេច

មាត្រា ១ : បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន ហៅថា " អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន " ដែលមានសមាសភាពដូចតទៅ :

១-សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១	សហប្រធាន
២-សម្តេច នាយករដ្ឋមន្ត្រីទី ២	សហប្រធាន
៣-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	អនុប្រធាន
៤-រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៥-ឯកឧត្តម ខិន មុន្នី អតីតប្រធានគណៈកម្មាធិការព្រំដែន ទីប្រឹក្សាប្រចាំអាជ្ញាធរ	
៦-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ	សមាជិក
៩-អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	សមាជិកអចិន្ត្រៃយ៍
១០-ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការ	

មាត្រា ២ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច ÷

-រៀបចំ និង កសាងលិខិតបទដ្ឋានគោលលក្ខណៈច្បាប់ស្តីពីការកំណត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រ ដើម្បីយកទៅតំកល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

-ស្រាវជ្រាវនិងសិក្សាអោយបានហ្មត់ចត់បំផុតក្នុងការជ្រើសរើសយកផែនទីលំនាំណាមួយសំរាប់ធ្វើការកំណត់បន្ទាត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រអោយបានច្បាស់លាស់ រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង ។

-ធ្វើការចរចា សំរបសំរួល ដោះស្រាយ និងសំរេចលើបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិត ខាងលើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីគណៈរដ្ឋមន្ត្រី ។

-សហប្រធានមានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ក្នុងនាមអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ៣ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការ២ ជាសេនាធិការ :

យន្តការទី ១ : ជាគណៈកម្មាធិការ ឬ ក្រុមការងារនីតិកម្មស្តីពីកិច្ចការព្រំដែន Task Force sur L'etude juridique មានសមាសភាពដូចតទៅ ÷

១-រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ប្រធាន
២-ឯកឧត្តម **ឌិត មុន្ទី** អតីតប្រធានគណៈកម្មាធិការព្រំដែន	ទីប្រឹក្សា
៣-អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	អនុប្រធាន
៤-តំណាងក្រសួងមហាផ្ទៃ	សមាជិក
៥-តំណាងក្រសួងការពារជាតិ	សមាជិក
៦-តំណាងអ្នកច្បាប់នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៧-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៨-តំណាងក្រសួងយុត្តិធម៌	សមាជិក
៩-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១០-ប្រធាននាយកដ្ឋានភូមិសាស្ត្រ	សមាជិក
១១-មន្ត្រីរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប	លេខាធិការ

គណៈកម្មការ ឬ ក្រុមការងារនីតិកម្មស្តីពីកិច្ចការព្រំដែន (Task Force sur L'etude juridique) នេះមានភារកិច្ច ÷

-ស្រាវជ្រាវដើម្បីរៀបចំឯកសារជាលក្ខណៈច្បាប់ (ទាំងព្រំដែនគោក និង ព្រំដែនសមុទ្រជាមួយប្រទេសជិតខាង) សំរាប់យកទៅតំកល់នៅអង្គការសហប្រជាជាតិ និង ធ្វើជាមូលដ្ឋានបង្អែកសំរាប់ពិភាក្សាជាមួយប្រទេសជិតខាង ។

-ធ្វើការចរចាជាមួយប្រទេសជិតខាង ក្នុងការកំណត់ជ្រើសរើសយកផែនទី សំរាប់ធ្វើការវាស់វែងខ្សែបន្ទាត់ព្រំដែន ។

ប្រការទី ២ : គឺជាគណៈកម្មាធិការ ឬ ក្រុមបច្ចេកទេសស្តីពីកិច្ចការព្រំដែន (Task Force Technique) ដែលមានសមាសភាពដូចតទៅ ៖

១-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	ប្រធាន
២-តំណាងក្រសួងការពារជាតិ	អនុប្រធាន
៣-តំណាងក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៤-តំណាងក្រសួងយុត្តិធម៌	សមាជិក
៥-តំណាងក្រសួងការបរទេស	សមាជិក
៦-អភិបាលគ្រប់ខេត្តជាប់ព្រំដែន	សមាជិក
៧-ប្រធាននាយកដ្ឋានភូមិសាស្ត្រ	សមាជិកអចិន្ត្រៃយ៍
៨-ប្រធាននាយកដ្ឋានសូរិយោដី	សមាជិក
៩-ប្រធាននាយកដ្ឋានរដ្ឋបាលព្រំដែន	សមាជិក
១០-មន្ត្រីរបស់ក្រសួងមហាផ្ទៃ ១រូប	ជាលេខាធិការ

គណៈកម្មាធិការ ឬ ក្រុមការងារបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះ មានខ្សែបណ្តាញភ្ជាប់ការងារកិច្ចការព្រំដែនរហូត ដល់ខេត្តនិងស្រុក ។ គណៈកម្មាធិការ ឬ ក្រុមបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះមានភារកិច្ចត្រួតពិនិត្យ ការពារបន្ទាត់ព្រំដែន ក្នុងរយៈរង់ចាំការដោះស្រាយធ្វើអន្តរាគមន៍ដោះស្រាយចំពោះបាតុភាពឬទំនាស់ព្រំដែន និងចុះធ្វើការវាស់វែងបោះគោល បន្ទាត់ព្រំដែនតាមស្មារតីនៃលទ្ធផលដែលទទួលបានពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ៤ : សមាជិកនៃគណៈកម្មាធិការទាំង២នេះ ត្រូវតែងតាំងដោយអនុក្រឹត្យតាមការចាត់តាំងរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ។

មាត្រា ៥ : គណៈកម្មាធិការនិមួយៗមានសិទ្ធិបង្កើតលេខាធិការដ្ឋាន ជាជំនួយការរដ្ឋបាល និង សំរបសំរួល ដែលមានទីស្នាក់ការនៅតាមក្រសួងសាមី ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការនិមួយៗត្រូវស្ថិតជាផ្នែកមួយរបស់លេខាធិការដ្ឋាន អចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។ ក្នុងករណីចាំបាច់គណៈកម្មាធិការនិមួយៗនេះអាចបង្កើតឬ ជ្រើសរើសអនុគណៈកម្មការផ្សេងៗដើម្បីសំរួល ឬបំពេញអោយមានប្រសិទ្ធភាពនូវការកិច្ចរបស់គណៈកម្មាធិការ ។

មាត្រា ៦ : យន្តការទាំងពីរនេះមានលេខាធិការដ្ឋានរួមមួយអចិន្ត្រៃយ៍ នៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រីហៅថា : លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមាន ÷

- អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសមាជិកអចិន្ត្រៃយ៍អាជ្ញាធរទទួលបន្ទុកលេខាធិការដ្ឋាន
- ប្រធាននាយកដ្ឋានភូមិសាស្ត្រអគ្គលេខាធិការអាជ្ញាធរជាប្រធានលេខាធិការដ្ឋាន
- ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែន ជាសមាជិក
- ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការបច្ចេកទេស ស្តីពីកិច្ចការព្រំដែន ជាសមាជិក
- មន្ត្រីជំនួយការមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះជាអ្នកសំរបសំរួលកិច្ចការ រវាងក្រុមការងារនីតិកម្មស្តីពីកិច្ចការព្រំដែននិងក្រុមបច្ចេកទេស ស្តីពីកិច្ចការព្រំដែន ហើយជាក្បាលម៉ាស៊ីនរដ្ឋបាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានភូមិសាស្ត្រ នាយកដ្ឋានសូរិយោដី មន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ និងមន្ត្រីនៃលេខាធិការដ្ឋានរបស់ យន្តការទាំង ២ សំរាប់ជំនួយការ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុក កិច្ចការព្រំដែនមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទទួលបន្ទុកកសាងផែនការចំណាយរបស់ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ៧ : លេខាធិការដ្ឋាន មានភារកិច្ច ÷

-សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធទៅនិងបញ្ហាព្រំដែន ដើម្បីរៀបចំ និងកសាងដោយផ្ទាល់អោយបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់សំរាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការ ព្រំដែន ។

-ចុះពិនិត្យនិងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និង សំរេច ។

-ចូលរួមចរចា ជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសំរាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេស អោយបានត្រឹមត្រូវច្បាស់ លាស់ ។

-សហការជាមួយអភិបាល ឬអភិបាលរងខេត្ត-ក្រុងដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាង ក្នុងការសិក្សាស្រាវជ្រាវលើទីតាំងព្រំដែន សីមា ជាក់ស្តែងទៅនឹងបញ្ហាបច្ចេកទេសជំនាញរួចរាយការណ៍អំពីលទ្ធផល ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍តាមតំណាក់កាលនិមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និង ការកំណត់ព្រំដែនជាមួយប្រទេសជិតខាង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនសំរាប់ រាយការណ៍ថ្នាក់និងជូនគណៈរដ្ឋមន្ត្រី ។

មាត្រា ៨ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រីសំរាប់សំរួលការងារ ។

សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

មាត្រា ៩ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនមានថវិកាដោយឡែក សំរាប់ចំណាយដោយផ្ទាល់ក្នុងការងាររបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១០ : សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ សម្តេចនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា រដ្ឋមន្ត្រីពាក់ព័ន្ធ រដ្ឋមន្ត្រីនិងអង្គភាពសាម៉ី និងតាមក្តីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ១១ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០២៩៤/២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ជាតិកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងអភិបាលខេត្ត ក្រុង

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល កម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **កែប ជុតិមា** ជាអភិបាលខេត្តរតនគិរី ជំនួសឯកឧត្តម **ខាំ ខឿន** ដែល បានទទួលមរណភាព ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយ បានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីពេលឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៧ អនក្រ

ស្ដីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្ដមទេសរដ្ឋមន្ត្រី ទទួលបន្ទុកការងារវប្បធម៌ វិចិត្រសិល្បៈរៀបចំទឹកដីនគរោបនីយកម្ម និង សំណង់

សំរេច

មាត្រា ១ : តែងតាំងលោក **ស៊ីម គង់** ជានាយកខុទ្ទកាល័យឯកឧត្ដម **វណ្ណ ម៉ូលីវណ្ណ** ទេសរដ្ឋមន្ត្រីទទួលបន្ទុក ការងារវប្បធម៌ វិចិត្រសិល្បៈ រៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការគ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន និងលោក **ស៊ីម គង់** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្ដម រណប្ញទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៨ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះលោក TONGSTIT LELAPRATAK, General Manager ក្រុមហ៊ុនពិភពពាណិជកម្ពុជា ដែលបានឧបត្ថម្ភប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិក សំរាប់ជួយទ្រទ្រង់ដល់ជីវភាពប្រជារាស្ត្រក្រីក្រ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៩ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ក្រិត្រប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- បានឃើញគុណបំណាច់របស់សប្បុរសជនក្នុងការជួយកសាងប្រទេសជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់អោយមេដាយស្ថាបនាជាតិថ្នាក់លេខ ២ ជូនចំពោះក្រុមហ៊ុនលោក **ណារ៉េ សុទ្ធិ** ដែលបានបរិច្ចាគប្រាក់ ៥.០០០ ដុល្លារអាមេរិក សំរាប់ជួយកសាងសាលារៀន នៅឃុំព្រៃដើមថ្នឹង ស្រុកស៊ិធរកណ្តាល ខេត្ត ព្រៃវែង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២០ អនក្រ
ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ១៩៩៤

សំរេច

មាត្រា ១ : ផ្ទេរលោក **ខាំ គង់** ប្រធានមន្ទីរ ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ទៅបំពេញការងារនៅរដ្ឋលេខាធិការដ្ឋានទំនាក់ ទំនងជាមួយសភា ។

មាត្រា ២ : ផ្ទេរក្របខ័ណ្ឌ និង បៀវត្សរាំប្រាក់ជូនទៅរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងលោក ដែលមានឈ្មោះក្នុងមាត្រា ១ ខាងលើត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ២១ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្ត តាកែវ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគទ្រព្យសម្បត្តិ ជួយកសាងអគារសិក្សានៅក្នុង ខេត្ត តាកែវ ដូចមានរាយនាមខាងក្រោមនេះ :

ក-ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះ :

១-លោក **គង់ ឃិន** និងអ្នកស្រី **គង់ ម៉េង** ទឹកប្រាក់ ១០.០៣៤ ដុល្លារអាមេរិក

២-លោក **សុក ភឿម** និងអ្នកស្រី **គង់ សៀក** ទឹកប្រាក់ ១០.០០៥ ដុល្លារអាមេរិក

ខ-ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ចំពោះលោក **កុំ ជេន** អ្នកស្រី **ហ៊ាន ឈឿន** និងលោក **ស៊ែម ចណ្ណៈ** ដែលបានបរិច្ចាគប្រាក់ ១.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២២ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ប្រគេន និងជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនចូលរួមកសាងព្រះវិហារវត្តបុរីប្រសិទ្ធិវង្ស ក្នុងឃុំព្រែកឡៅ ស្រុកពញាឮ ខេត្ត កណ្តាល ដូចមានរាយនាម និងព្រះនាមខាងក្រោមនេះ ÷

ក-អោយមេដាយស្ថាបនាជាតិថ្នាក់មាស ១ :

១-ព្រះចៅអធិការវត្តធម្មរាជ្យតេជោ **មូខ រ៉ា** ព្រះសមុហ៍អនុគណៈស្រុកបានប្រមូលបច្ច័យសរុប ៥៥៩.០៨០ ដុល្លារអាមេរិក

២-ឯកឧត្តម **ឆៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

៣-ឯកឧត្តម **ឆា ចំរ៉ាក់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

៤-ឯកឧត្តម **ណិម សុធត្ថិ** ក្រសួងការពារជាតិទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

ខ-ជូនមេដាយស្ថាបនាជាតិថ្នាក់មាស ២ :

១-លោកស្រី **លី សុខា** ទឹកប្រាក់ ៩.៤០០ ដុល្លារអាមេរិក

២-លោកយាយ **អៀង ជូ** ទឹកប្រាក់ ៦.០០០ ដុល្លារអាមេរិក

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២២ អនក្រ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់អភិបាលខេត្តកណ្ដាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ប្រគេន និងជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនចូលរួមកសាងព្រះវិហារវត្តមុនីប្រសិទ្ធិវង្ស ក្នុងឃុំព្រែកឬស្សី ស្រុកពញាឮ ខេត្ត កណ្ដាល ដូចមានរាយនាម និងព្រះនាមខាងក្រោមនេះ ÷

ក-អោយមេដាយស្ថាបនាជាតិថ្នាក់លេខ ១ :

១-ព្រះចៅអធិការអគ្គាធិបតី **មួច រ៉ា** ព្រះសមុហ៍អនុគណៈស្រុកបានប្រម្ចូលបច្ច័យសរុប ៥៥៩.០៥០ ដុល្លារអាមេរិក

២-ឯកឧត្តម **ខៀវ ចាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

៣-ឯកឧត្តម **ឆា ចំរ៉ាក់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

៤-ឯកឧត្តម **ណឹម សុខគ្គី** ក្រសួងការពារជាតិទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

ខ-ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ២ :

១-លោកស្រី **លី សុខា** ទឹកប្រាក់ ៥.៤០០ ដុល្លារអាមេរិក

២-លោកយាយ **អៀង ជូ** ទឹកប្រាក់ ៦.០០០ ដុល្លារអាមេរិក

៣_លោក ម៉ូ ចាន់ថាច ទឹកប្រាក់ ៦.០០០ ដុល្លារអាមេរិក

៤_លោកស្រី លឹម សៀកឆឹម ទឹកប្រាក់ ៥.៦០០ ដុល្លារអាមេរិក

៥_លោកស្រី ខៅ សៀងឡេង ទឹកប្រាក់ ៥.៦០០ ដុល្លារអាមេរិក

៦_លោកស្រី ម៉ៅ សាយគឹម ទឹកប្រាក់ ៥.៦០០ ដុល្លារអាមេរិក

៧_លោកស្រី លឹម សំបូរ ទឹកប្រាក់ ៥.៦០០ ដុល្លារអាមេរិក

៨_លោក ហ៊ូ ឡុង ទឹកប្រាក់ ៥.៦០០ ដុល្លារអាមេរិក

៩_លោកស្រី លឹម លីឡេង ទឹកប្រាក់ ៥.៦០០ ដុល្លារអាមេរិក

១០_លោកស្រី ថោង ហៀង ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

១១_លោក ប៊ុក ចាន់ធូ ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

១២_លោកស្រី ឈឹម ម៉ារី ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

១៣_លោក ម៉ា រុន ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

គ_ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ៖

១_លោក កេង ហ៊ី ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

២_លោក អូន សៀ ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៣_លោក យូ ហួត ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៤_លោក ម៉ែត ជួន ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៥_លោក គាន់ ណាង ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៦_លោក ម៉ាក់ សារឿន ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៧_លោក ម៉ក់ លី ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៨_លោក ម៉ាញ ចាន់ ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

មាត្រា ២ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យបានទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

សេចក្តីសំរេចលេខ ១៩ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីក្រសួងផែនការស្តីទី ជំនួសឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ដែលជាប់អញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ រហូតដល់ពេលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាននិងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២០ សសរ
ស្តីពីការបង្កើតក្រុមការងារ « TASK FORCE » មួយដើម្បីចរចា និង សំរបសំរួលការងារ ជាមួយក្រុមហ៊ុន ARISTON

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : បង្កើតក្រុមការងារ " TASK FORCEE " មួយដើម្បីចរចា និង សំរបសំរួលការងារវិនិយោគទុន លើវិស័យផ្សេងៗ របស់ក្រុមហ៊ុន ARISTON នៅទីក្រុងព្រះសីហនុ ដែលមានសមាសភាព ដូចខាងក្រោម :

១_ឯកឧត្តមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ		ជាប្រធាន
២_តំណាងក្រសួងទេសចរណ៍	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៣_តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៤_តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៥_តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៦_តំណាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៧_តំណាងក្រសួងគ្រប់គ្រងបរិស្ថាន	" ថ្នាក់នាយកដ្ឋាន "	ជាសមាជិក
៨_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី		ជាសមាជិក
៩_តំណាងក្រុងព្រះសីហនុ		ជាសមាជិក

១៧_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិកអចិន្ត្រៃយ៍ និង ជាលេខាធិការប្រចាំការ

ប្រការ ២ : ក្រុមការងារ " TASK FORCE " នេះមានភារកិច្ចដូចតទៅ :

-ធានា សំរបសំរួលការងារ លើគំរោងវិនិយោគទុន របស់ក្រុមហ៊ុន ARISTON ។

-ធ្វើរបាយការណ៍ពីលទ្ធផលពិភាក្សា និង ពិនិត្យសិក្សាផ្តល់មតិ លើរាល់ឯកសារពាក់ព័ន្ធព្រមទាំង លើកវិធានការចាំបាច់ផ្សេងៗដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ប្រការ ៣ : សមាជិកទាំងអស់នៃក្រុមការងារ " TASK FORCE " នេះត្រូវចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និង ការណែនាំរបស់ប្រធាន ។

ប្រការ ៤ : ក្រុមការងារ " TASK FORCE " នេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាផ្លូវការ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន អភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តសេចក្តីសំរេចនេះ តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

III- ភាគខាងបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សេចក្តីណែនាំ - ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សេចក្តីណែនាំលេខ ០៣២ សហវ.សណន
ស្តីពីការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលតាម
ក្រសួងស្ថាប័ន នៅរដ្ឋបាលកណ្តាលនិងតាមមន្ទីរនានានៅខេត្ត-ក្រុង

ផ្អែកតាមសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៥ របស់រដ្ឋាភិបាលស្តីពីការកែទំរង់រដ្ឋបាលសាធារណៈ និង សារាចរលេខ ០១.សរ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលស្តី ពីការរាប់ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រោយពីកិច្ចប្រតិបត្តិការរាប់ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ មកពានក្រសួងស្ថាប័នខេត្ត-ក្រុង មួយចំនួនបើកប្រាក់បៀវត្សជូនមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួនមានការយឺតយ៉ាវដោយនៅមិនទាន់យល់ ច្បាស់ពីមូលដ្ឋានដែលត្រូវបើកបៀវត្សជាពិសេសនៅតាមខេត្ត-ក្រុងខ្លះ ។

ដើម្បីជំរុញការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការអោយបានទាន់ពេលវេលានិងប្រកបដោយជោគជ័យនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ÷

១-ជំហានទី ១ : ត្រូវបើកប្រាក់បៀវត្សជូនចំពោះតែមន្ត្រីរាជការស៊ីវិលណា ដែលពានសាលាកប័ត្រមន្ត្រីរាជការនិងវិញ្ញាបនប័ត្រ បើកបៀវត្សដែលបានធ្វើនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

២-ជំហានទី ២ :ចំពោះមន្ត្រីរាជការដែលអវត្តមានដោយមានមូលហេតុច្បាស់លាស់ដូចជា ÷

- អ្នកកំពុងតែសិក្សាមានរយៈពេលខ្លី ឬ វែងហើយមានលិខិតចាត់តាំងត្រឹមត្រូវ
- អ្នកដែលត្រូវអនុញ្ញាតិច្បាប់អោយឈប់សំរាករយៈពេលយូរ សំរាលកូន ឬមានជម្ងឺរ៉ាំរ៉ៃ ឬត្រូវបានអនុញ្ញាតអោយទៅព្យាបាលជម្ងឺនៅបរទេស
- អ្នកត្រូវបានអនុញ្ញាតអោយចុះបំពេញបេសកកម្ម ដោយមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ

-មន្ត្រីរាជការមួយចំនួនធ្វើការនៅតំបន់ដាច់ស្រយាលដូចជានៅខេត្តភូមិភាគឥសាន ឬនៅខេត្តដទៃទៀតដែលមានសភាពការណ៍អសន្តិសុខ ឬខ្វះមធ្យោបាយធ្វើដំណើរ មិនអាចឡើងមក ទាន់ពេលវេលាដើម្បីបំពេញសលាកប័ត្រមន្ត្រីរាជការ និង វិញ្ញាបនប័ត្របើកបៀវត្ស

-អ្នកមានលិខិត ឬ សេចក្តីសំរេចផ្សេងៗទៀតដែលស្របច្បាប់ ។

ចំពោះមន្ត្រីរាជការស៊ីវិលដែលអវត្តមាន មានមូលហេតុតាមមុខសញ្ញាដូចបានបញ្ជាក់ខាងលើនេះនៅបន្តបើកប្រាក់បៀវត្សដូចធម្មតា ប៉ុន្តែប្រធានអង្គភាពគ្រប់គ្រងសាមីជននោះផ្ទាល់ត្រូវធ្វើរបាយការណ៍បញ្ជាក់ទទួលខុសត្រូវពីមូលហេតុច្បាស់លាស់ ដោយមានចុះហត្ថលេខារបស់មន្ត្រីតំណាងប្រធានបុគ្គលិកនិងតំណាងប្រធានគណនេយ្យ ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាលើសលាកប័ត្រមន្ត្រី រាជការនិងវិញ្ញាបនប័ត្របើកបៀវត្ស នាថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ព្រមទាំងមានការបញ្ជាក់ពីឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ ចំពោះក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាលនិងនៅតាមខេត្តក្រុងត្រូវមានបញ្ជាក់ពីអភិបាលខេត្ត ក្រុង រួចបញ្ជូនរបាយការណ៍ នេះមួយច្បាប់ជូនគណៈគណៈកម្មការត្រួតពិនិត្យមន្ត្រីរាជការស៊ីវិលនៅគណៈរដ្ឋមន្ត្រី ដើម្បីជ្រាប ។

៣-ជំហានទី ៣ : ចំពោះមន្ត្រីរាជការទាំងឡាយណា ដែលមានចេញលិខិតទទួលស្គាល់គ្រប់ខ័ណ្ឌពីគណៈរដ្ឋមន្ត្រីឬ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ហើយត្រូវបានក្រសួង ឬ ស្ថាប័នខេត្ត-ក្រុង ចេញប្រកាសតែងតាំងប្រគល់ការងារជូនហើយនោះ ត្រូវរៀបចំបញ្ចូលក្នុងតារាងបៀវត្សដើម្បីរាយការណ៍សុំមកគណៈរដ្ឋមន្ត្រី " គណៈកម្មការត្រួតពិនិត្យរាប់មន្ត្រីរាជការ " សំរេចបើកបៀវត្សជូន ។

៤-ចំពោះមន្ត្រីរាជការ ដែលអវត្តមានដោយគ្មានមូលហេតុគឺមិនអនុញ្ញាតអោយបើកប្រាក់បៀវត្សជូនទេ ទោះបីក្រោយថ្ងៃរាប់មានលិខិតសុំតវ៉ាក៏ដោយ ត្រូវរង់ចាំសេចក្តីសំរេចរបស់គណៈកម្មការត្រួតពិនិត្យមន្ត្រីរាជការស៊ីវិលនៅគណៈរដ្ឋមន្ត្រី ។

ដោយយោងតាមខ្លឹមសារខាងលើនេះ ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់បើក បៀវត្សជូនមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួនអោយបានទាន់ពេលវេលា ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

***

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៣៣ ប្រក.សហវ ធរ

ស្តីពី

សេចក្តីយល់ព្រមអោយក្រុមហ៊ុន

INDOCHINE INSURANCE UNION

សហការបច្ចេកទេសជាមួយកាមិនភូជើម្បីធានារ៉ាប់រង

លើការអនុវត្តន៍គំរោងរបស់អង្គការសហគមអឺរ៉ុប PRASAC-3

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងហិរញ្ញវត្ថុ ។
- បានឃើញច្បាប់ស្តីពីការបង្កើតអាជីវកម្មធានារ៉ាប់រង ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១៣ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការគ្រប់គ្រង អាជីវកម្មធានារ៉ាប់រង ។

-បានឃើញសេចក្តីជូនដំណឹងលេខ ១៥៣០ សជណ.ពាហ របស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩២ ស្តីពីការអនុញ្ញាតជាគោលការណ៍អោយក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ចាប់ដំណើរការអាជីវកម្មដោយផ្ទាល់ខ្លួនឯង ចាប់ពីដើមត្រីមាសទី ៤ ឆ្នាំ ១៩៩២ តទៅ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន INDOCHINE INSURANCE UNION សហការបច្ចេកទេសជាមួយក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា " កាមិនកូ " ក្នុងការធ្វើសកម្មភាពជាអ្នកធានារ៉ាប់រងលើការអនុវត្តគំរោងរបស់ អង្គការសហគមអឺរ៉ុប " PRASAC-3 " ។

ប្រការ ២ : ការិយាល័យតំណាងរបស់ក្រុមហ៊ុន INDOCHINE INSURANCE UNION នៅភ្នំពេញអាចធ្វើសកម្មភាពលើវិស័យធានារ៉ាប់រងនៅ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានតែក្នុងរង្វង់នៃការអនុវត្តគំរោងរបស់អង្គការសហគមអឺរ៉ុប " PRASAC-3 " ប៉ុណ្ណោះ ។

ប្រការ ៣ : កិច្ចប្រតិបត្តិការផ្សេងៗ ទៀតជាអ្នកធានារ៉ាប់រងរបស់ការិយាល័យ តំណាងក្រុមហ៊ុន INDOCHINE INSURANCE UNION មិនស្ថិតនៅក្រោមអនុភាពនៃសេចក្តីយល់ព្រមនេះទេ ។

ប្រការ ៤ : សេចក្តីយល់ព្រមនេះ អស់ប្រសិទ្ធភាពអនុវត្ត នៅពេលដែលគំរោងរបស់អង្គការសហគមអឺរ៉ុប PRASAC-3 ត្រូវបាន បញ្ចប់ជាស្ថាពរ ។

ប្រការ ៥ : កំហុសទាំងឡាយ ក្នុងការអនុវត្តសេចក្តីយល់ព្រមនេះ ក្រុមហ៊ុន INDOCHINE INSURANCE UNION និងការិយាល័យតំណាងនៅភ្នំពេញត្រូវទទួលតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

២. ធីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៧២ ពណ.បល.ប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងសេចក្តីកំណត់ស្តីអំពីរបៀបរបបធ្វើការនៃក្រសួងពាណិជ្ជកម្មលេខ ១៨៧៧ ពណ.របល ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ។

-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្តម **ខៀវ វ៉ាដា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ក្នុងការចុះហត្ថលេខា សំរេចលើលិខិតបទដ្ឋាននានា អំពីការសុំបង្កើតនិងរំសាយក្រុម ហ៊ុនសហគ្រាសពាណិជ្ជកម្មឯកជន ។

ប្រការ ២ : ត្រូវបានប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្តម **គុម សំ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ក្នុងការចុះហត្ថលេខា សំរេចលើលិខិតបទដ្ឋាននានារបស់មជ្ឈមណ្ឌលជាតិប្រព័ន្ធអនុគ្រោះទូទៅ GSP ។

ប្រការ ៣ : ប្រធានមន្ទីរ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស និង ឯកឧត្តមអនុរដ្ឋលេខាធិការទាំងពីររូប ត្រូវទទួលអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

៣- ធីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៨៦ ប្រក.កសក ស្តីពីអាករអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំង របស់ក្រសួងកសិកម្ម
- បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៨៧ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ [illegible] ស្តីពី[illegible] និង កន្លែងពិឃាតសត្វ
- បានឃើញប្រកាសលេខ ៥៧ ប្រក.កសក.ម ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីអាករអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- តាមសំណើរបស់នាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យ

សំរេច

មាត្រា ១ : អង្គភាពរដ្ឋ អង្គភាពរដ្ឋចំរុះឯកជន ក្រុមហ៊ុន សហគ្រាសឯកជន ដែលធ្វើអាជីវកម្មសត្វ និង ផលិតផលមានដើម កំណើតពីសត្វ ត្រូវបង់អាករអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ លើកលែងតែអង្គភាពរដ្ឋ ឬប្រជាពលរដ្ឋ ដែលទិញ-ដូរសត្វ ដើម្បីយកទៅចិញ្ចឹមធ្វើពូជកំលាំងអូសទាញ ឬ ធ្វើការពិសោធន៍ស្រាវជ្រាវ ។

មាត្រា ២ : អាករអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវបានបែងចែកជា :

អាករត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វដែលធ្វើចរាចរផ្ទៃក្នុងប្រទេស ។

-អាករត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ដែលធ្វើចរាចរចូលក្នុងផ្ទៃប្រទេសចេញក្រៅប្រទេស ។

អាករទាំងនេះត្រូវបានកំណត់តាមតារាងដូចខាងក្រោម :

ល.រ	ប្រភេទសត្វនិងផលិតផលមានដើមកំណើតពីសត្វ	ឯកតា	ធ្វើចរាចរក្នុងប្រទេស « រៀល »	ធ្វើចរាចរចូលក្នុង ឬ ចេញក្រៅប្រទេស "ដុល្លារអាមេរិក"
១	សត្វចតុបាទ ព្រៃ តូចធំ	ក្បាល	៣.០០០	១០.០០
២	សត្វចតុបាទស្រុក តូច ធំ	-	១.០០០	២.០០
៣	បក្សីស្រុក	-	៣០	០.១០
៤	បក្សីព្រៃ	-	១.០០០	៥.០០
៥	សត្វលូន សត្វវារ	-	១.០០០	៥.០០
៦	មច្ឆាជាតិតំលៃទាប	តោន	-	០,៥០
៧	មច្ឆាជាតិតំលៃខ្ពស់	-	-	៥.០០
៨	ពពួកបង្កង មឹក	-	-	៥.០០
៩	ពពួកងៀវ គ្រុំ	-	-	៣.០០
១០	ស៊ុតស្រស់ និង ប្រៃ	១០០ គ្រាប់	១០	០.១០

១១	ទឹកឃ្មុំ	លីត្រ	២០	0.0៥
១២	ក្រមួនឃ្មុំ	គ.ក្រ	២០	0.0១
១៣	គ្រឿងបរិភោគផ្សំអំពីផលិតផលសត្វ	–	២០	0.0៥
១៤	ទឹកដោះ និង ផលិតផលផ្សំពីទឹកដោះ	–	២០	0.0៥
១៥	សាច់ពន្លាស់ស្រស់ ឬ បង្កក	–	១០	0.0២
១៦	សាច់ជាប់ឆ្អឹងស្រស់ ឬ បង្កក	–	១០	0.0២
១៧	សាច់ងៀត ឬ ក្រក	–	៣០	0.0៣
១៨	ត្រីងៀត ត្រីឆ្អើរ	–	–	0.0២
១៩	ប្រហុក	–	–	0.0១
២០	ខ្លាញ់ស្រស់	–	១០	0.0១
២១	ខ្លាញ់រាវ	–	២០	0.0៥
២២	ឆ្អឹង	–	១០	0.0១
២៣	ស្បែកស្រស់ប្រឡាក់អំបិល	–	១០	0.0៣
២៤	ស្បែកស្ងួត	–	២០	0.១0
២៥	រោម_ស្លាប បក្សីស្រុក	–	២០	0.0២
២៦	រោម_ស្លាប បក្សីព្រៃ	–	២០	0.៥
២៧	រោមសត្វចតុបាទ	–	២០	0.0៣
២៨	ស្នែងសត្វចតុបាទស្រុក	–	២០	0.0២
២៩	ស្នែងសត្វចតុបាទព្រៃ	–	២.000	៥.00
៣០	ភ្លុក	–	២.000	៥.00
៣១	សំបក ទ្រូងអណ្តើក		១00	0.១

ឈ្មោះសត្វ និង បណ្តាផលិតផលដទៃទៀត ដែលមានដើមកំណើតពីសត្វ អាចបំពេញបន្ថែមក្នុងតារាងខាងលើ ប្រសិនបើមានការចាំបាច់ ។

ក្នុងករណីត្រូវចាក់ថ្នាំការពារព្យាបាលសត្វ ឬ ការងារចាំបាច់ផ្សេងៗទៀត រាល់ការចំណាយទាំងអស់ ជាបន្ទុករបស់ម្ចាស់សត្វ ។

មាត្រា ៣ : ប្រាក់ចំណូលនៃអាករដែលអង្គភាពត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វទទួលបាន ត្រូវអនុវត្តដូចតទៅ :

ក-ផ្នែកផលិតកម្ម និង បសុព្យាបាលស្រុក-ខ័ណ្ឌ ត្រូវយកប្រាក់ចំណូលនៃអាករទៅបង់នៅការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត-ក្រុង ។

ខ-ការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត-ក្រុង ត្រូវយកប្រាក់ប្រមូលបានទៅបង់ចូលថវិការដ្ឋនៅរតនាគារ ខេត្ត-ក្រុង ហើយត្រូវធ្វើរបាយការណ៍ភ្ជាប់នឹងសលាកប័ត្របង់ចូលថវិការដ្ឋ មកនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជារៀងរាល់ខែ ។

គ-នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល ត្រូវយកចំណូលដែលប្រមូលបានពីអាករទៅបង់ចូលថវិការដ្ឋនៅរតនាគារជាតិ ហើយត្រូវធ្វើរបាយការណ៍អំពីចំណូលនេះ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជារៀងរាល់ខែ ។

មាត្រា ៤ : នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានភារកិច្ចត្រួតពិនិត្យពីការអនុវត្តយកអាកររបស់ការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត-ក្រុង ។ ក្នុងករណីជួបការលំបាកស្មុគ្រស្មាញ ត្រូវរាយការណ៍ជាបន្ទាន់ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីមានវិធានការដោះស្រាយ ។

មាត្រា ៥ : ប្រកាសលេខ ៥៧ ប្រក.កសក.ប ចុះថ្ងៃទី ០១-០២-៩០ និង បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋាន គណនេយ្យ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ ប្រធានគណៈកម្មាធិការ ត្រួតពិនិត្យ ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល ប្រធានមន្ទីរកសិកម្ម

ខេត្ត-ក្រុង ប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត-ក្រុង ប្រធានផ្នែកផលិតកម្ម និង បសុព្យាបាលស្រុក-ខ័ណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៧ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ម៉ៅ សំអឿន

***

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៩៣ ប្រក.កសក
ស្តីពីការលក់ចក្ខុគាថរីបអូសនៃ
ចងល្មើសនេសាទសមុទ្រ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៅតាម ក្រសួងស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល

-បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធ ចាត់តាំងក្រសួងកសិកម្ម

-បានឃើញកំណត់ហេតុ ចុះថ្ងៃទី ១៦-២-៩៥ ស្តីពីការដេញថ្លៃលក់វត្ថុតាងរឹបអូស នៃបទល្មើសនេសាទសមុទ្រ

សំរេច

ប្រការ ១ : -លក់ជូនឈ្មោះ **មាស ចំរើន** ជាប្រជាជននៅឃុំច្បារអំពៅ ស្រុកមានជ័យ រាជធានីភ្នំពេញ ដែលជាអ្នកហ៊ានអោយថ្លៃខ្ពស់ជាងគេ នូវទូកយន្តនេសាទអំពីឈើចំនួន ពីរគ្រឿង ដែលត្រូវរឹបអូសតាមសាលក្រមរបស់តុលាការក្រុងព្រះសីហនុ លេខ ៤៥ ចុះថ្ងៃទី ១៧-៦-៩៤ គឺទូកយន្តទំហំ ២៩.៦មx២ម៉ុ២០ ដាក់ម៉ាស៊ីនម៉ាកអ៊ីណូ កំលាំង ៣៥០ សេះ គុណភាពល្អ៦០ភាគរយ ចំនួន ០១ គ្រឿង និងទូកយន្តទំហំ " ៨ម.២ម៉ុ៥០.៤ម៉ុ៥០ " ដាក់ម៉ាស៊ីនម៉ាកអ៊ីណូ កំលាំង ១៥០ សេះ គុណភាពល្អ ៦០ភាគរយ ចំនួន ០១គ្រឿង ។

លក់ជូនអ្នកស្រី **កៅ សារ៉េយ** ជាប្រជាជននៅសង្កាត់លេខ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលហ៊ានអោយថ្លៃ ខ្ពស់ជាងគេនូវឧបករណ៍អួនស្បៃមុងទំហំ " ៣៦៨ម.៤៥ម.០ម៉ុ០០៣ " គុណភាពល្អ ៦០ភាគរយ ចំនួន ០១ វង់ ។

ប្រការ ២ : -ថ្លៃលក់ទូកយន្តទាំងពីរគ្រឿងខាងលើនេះមានចំនួន " ៥៤.៦០០.០០០រ៛០០ " " ហាសិបបួនលានប្រាំមួយរយ ពាន់រៀល " ។

-ថ្លៃលក់ឧបករណ៍អួនស្បៃមុងខាងលើនេះមានចំនួន ១៣.០០០.០០០រ៛០០ " ដប់បីលានរៀល " ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានជលផល-ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយនិងសាមីខ្លួន ត្រូវអនុវត្តសេចក្តីប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ហត្ថលេខា និង ត្រា

តាវ សេងហួរ

***

៤. ឋិស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៧/៩៥ ពម.ប្រក

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

សំរេច

ប្រការ ១ : អត្ថបទជាលាយលក្ខណ៍អក្សរគ្រប់បែបយ៉ាង លើកលែងតែលិខិតបោះពុម្ពរាយរង ដូចជាបណ្ណ័អញ្ជើញ នាមប័ណ្ណ ស្រោមសំបុត្រ លិខិតបោះពុម្ពខាងរដ្ឋបាលដែលផ្សព្វផ្សាយជាសាធារណៈ ត្រូវទទួលទិដ្ឋាការ និង លេខតំកល់ទុកតាមផ្លូវ ច្បាប់ ពីក្រសួងពត៌មាន ។

ប្រការ ២ : គ្រប់ការបោះពុម្ពផ្សាយ ដូចមានចែងក្នុងប្រការ ១ ត្រូវមានបញ្ជាក់ឈ្មោះ អាសយដ្ឋានរបស់រោងពុម្ព និង ចំនួនច្បាប់បោះពុម្ព ហើយត្រូវបញ្ជូនទៅតំកល់ទុកនៅ ក្រសួងពត៌មាន ចំនួន ០២ ច្បាប់ ។

ប្រការ ៣ : ក្នុងករណីឯកសារ ព្រឹត្តប័ត្រ ឬ សៀវភៅគ្មានទិដ្ឋាការ ឬ លេខតំកល់ទុកពីក្រសួងពត៌មានរោងពុម្ពដែលទទួលបោះពុម្ពនោះ ដោយមានម្ចាស់រោងពុម្ពជាអ្នកទទួលខុសត្រូវផ្ទាល់ ត្រូវទទួលការផ្តន្ទាទោស តាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៨/៩៥ ពម.ប្រក
ស្តីពីការលុបឈ្មោះ មន្ត្រីរាជការ
នៅមន្ទីរពត៌មាន ខេត្ត កណ្តាល

-យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ពិនិត្យលើចំណារបញ្ជូនលេខ ០១៨ ព.ម.ខ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មាន ខេត្ត កណ្តាល

-ពិនិត្យលើសភាពការណ៍ជាក់ស្តែង

សំរេច

ប្រការ ១ : លុបឈ្មោះ អ្នកស្រី **ពៅ ដានីធីកា** ចេញពីក្របខ័ណ្ឌរបស់មន្ទីរពត៌មាន ខេត្ត កណ្តាល ចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៥ នេះតទៅ ដោយសាមីខ្លួនស្ម័គ្រចិត្តសុំឈប់បំរើការងារ ។

ប្រការ ២ : អ្នកស្រី **ពៅ ដានីធីកា** ដូចបានចែងក្នុងប្រការ ១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងប្រាក់បៀវត្ស :

អ្នកស្រី **ពៅ ដានីធីកា** : ២៩.២៨០៛ គុណ ៨ : ២៣៤.២៤០៛០០ " ពីររយសាមសិបបួនពាន់ ពីររយសែសិបរៀលគត់ "

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពត៌មាន ខេត្ត កណ្តាល និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៩/៩៥ ពម.ប្រក
ស្ដីពីការលុបឈ្មោះ មន្ត្រីរាជការ នៃ
មន្ទីរពត៌មាន ខេត្ត កំពង់ចាម

-យោងព្រះរាជក្រឹត្យ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ពិនិត្យលើលិខិតបញ្ជូនរបស់មន្ទីរពត៌មាន ខេត្ត កំពង់ចាម លេខ ០៣ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ១៩៩៥

-ពិនិត្យលើពាក្យសុំឈប់បំរើការងារ របស់សាមីខ្លួន ។

សំរេច

ប្រការ ១ : លុបឈ្មោះ អ្នកស្រី **សុខ ស្រី** បុគ្គលិកមន្ទីរពត៌មាន ខេត្ត កំពង់ចាម ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដោយសាមីខ្លួនស្ម័គ្រចិត្តសុំឈប់បំរើការងារ ។

ប្រការ ២ : អ្នកស្រី **សុខ ស្រី** ដូចបានចែងក្នុងប្រការ ១ ត្រូវទទួលប្រាក់ឧបត្ថម្ភម្ដងគត់ស្មើនឹងប្រាក់បៀវត្សអ្នកស្រី **សុខ ស្រី** ត្រូវទទួលប្រាក់ ៣២.១១០រ០០ គុណ ១០ : ៣២១.១០០រ០០ " បីរយម្ភៃមួយពាន់មួយរយរៀលគត់ " ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្ត កំពង់ចាម និងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

***

៥. ធីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៣៩ បទ.ប្រក

ស្តីពីការតែងតាំង បជិន្ទាហកៈមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា ១៩៩៤ និង ប្រកាសអោយប្រើនៅថ្ងៃទី ២០ កក្កដា ១៩៩៤

-បានឃើញប្រកាសលេខ ០៨២ ប្រក.បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំរចនាសម្ព័ន្ធមន្ទីរប្រៃ សណីយ៍ និង ទូរគមនាគមន៍ ខ្សែរយៈបណ្តោយគ្រប់ខេត្ត-ក្រុង

-បានឃើញសំណូមពរនិងការឯកភាពរបស់អភិបាលខេត្តបន្ទាយមានជ័យ លេខ ៦៦ ខបជ ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ ១៩៩៥

-ពិនិត្យសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០១ រូបដូចមានឈ្មោះខាងក្រោមជា បជិន្ទាហកៈរង នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្ត បន្ទាយមានជ័យ ។

១-លោក ឃុំ គីលីន បជិន្ទាហកៈរង

ប្រការ ២ : នាយកខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ , នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស , នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ , នាយកដ្ឋានប្រៃសណីយ៍ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៣ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ស៊ូ ឃុន

***

៦. ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤០២/ប.ស្ថ
ស្តីពីការផ្ទេរភារកិច្ចជូន
មន្ត្រីរាជការក្រសួងគ្រប់គ្រងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ។
- យោងលិខិតស្នើសុំលេខ ១៦ ពស.រស ចុះថ្ងៃទី ០៩ ខែ ០១ ឆ្នាំ ១៩៩៥ របស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។
- យោងតាមការឯកភាពរបស់រដ្ឋលេខាធិការ ចុះថ្ងៃទី ១៣ ខែ ០១ ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : ផ្ទេរលោក **ឈុំ សុខា** បុគ្គលិកបំពេញការងារនៅនាយកដ្ឋានផែនការបរិដ្ឋានគ្រប់គ្រងទឹក និងប្រើប្រាស់ដីនៃក្រសួងគ្រប់គ្រងបរិដ្ឋាន ទៅបំពេញការងារនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រាក់បៀវត្ស និង របបឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួនក្រសួងគ្រប់គ្រងបរិស្ថានផ្តាច់ប្រាក់បៀវត្ស ពីអង្គភាពដើមថ្ងៃទី ០១ ខែ ៣ ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ខុទ្ទកាល័យ អង្គភាពដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

***

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤០៣ បស្ថ.ចក
ស្តីពីការតែងតាំងភ្នាធិការកិច្ច

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ។

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស.រកត ១០.៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-យោងសំណើរបស់លោកប្រធានមន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តកំពង់ចាមលេខ ១៣ បស្ថ.កចចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការ ០២ រូប ជាអនុប្រធានមន្ទីរ គ្រប់គ្រងបរិដ្ឋាន ខេត្តកំពង់ចាម :

១-លោក **ឈុំ ប៊ុនធឿន**

២-លោក **ឧូច គីមហ៊ុន**

ប្រការ ២ : អគ្គនាយក ខុទ្ទកាល័យ មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តកំពង់ចាម អង្គភាពដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

***

៧. ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤០/៩៥ កធស.ប្រក
ស្តីអំពីការទទួលស្គាល់សមាសភាព
មន្ត្រីរាជការរបស់ខេត្ត មណ្ឌលគិរី

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង ធម្មការ និង សាសនា ។
- បានឃើញលេខ ២០០.៩៤ ល.ស ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់អភិបាលខេត្តមណ្ឌលគិរី

សំរេច

ប្រការ ១ : ទទួលស្គាល់សមាសភាពបុគ្គលិកមន្ត្រីរាជការក្នុងក្របខ័ណ្ឌរបស់មន្ទីរធម្មការ និង សាសនា ខេត្តមណ្ឌលគិរី ១៥ នាក់ចាប់ពីថ្ងៃទី ០១-០១-១៩៩៥ ដូចមានរាយនាមខាងក្រោម :

១_លោក **នេត គន្ធា**

២_លោក **ទ្រេសខ សុក**

៣_លោក **ធេព កុសល**

៤_លោក **ទ្រេសមសុភាព**

៥_លោក **ណាល់ ពិដោ**

៦_ លោក **នួន សុឃុន**

៧_លោក **រិតថៃ**

៨_លោក **រីកចហៀន**

៩_លោក **រត្ន័ សារ៉េត**

១០_លោក **ពៅ៉ប្រុចាចស្រុកកោះញែក "**

១១_លោក **ប្រុម៉ មាលី** " ស្រុកពេជ្រដា "

១២_លោក **ឆន ឈុន** " ស្រុកសែនមនោរម្យ "

១៣_លោក **ទ្រីសម ឈឿស** " ស្រុកអូររាំង "

១៤_លោក **ម៉ាំខ សុខន** " ស្រុកកែវសីមា "

១៥_លោក **តុយ ម៉ៅ** " ស្រុកកែវសីម៉ា "

ប្រការ ២ : មន្ទីរធម្មការ និង សាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុ ខេត្តមណ្ឌលគិរី និងអស់លោកដែលមានឈ្មោះក្នុងប្រការមួយដើម្បីអនុវត្តរៀងៗខ្លួន ។

ប្រការ ៣ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

ហត្ថលេខា និង ត្រា

ហៀន វណ្ណារត្ន័

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៧/៩៥ កធស.ប្រក
ស្តីពីការតែងតាំងមន្ត្រីរាជការ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣

-បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។

-បានឃើញសំណើតម្លើងឋានៈលោក ស៊ុម អ៊ុម លេខ ១៤.៩៥ ចុះថ្ងៃទី ២០ កុម្ភៈ ១៩៩៥ របស់នាយកដ្ឋានធម្មការ ។

-យោលទៅលើការងារចាំបាច់របស់ក្រសួងនិងសមាសភាពរបស់មន្ត្រីរាជការ ។

សំរេច

ប្រការ ១ : លោក **ស៊ុម អ៊ុម** បច្ចុប្បន្នជាប្រធានការិយាល័យធម្មការ ជាអនុប្រធាននាយកដ្ឋានធម្មការ ។

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច ការិយាល័យបុគ្គលិក និង លោក ស៊ុម អ៊ុម ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
ហត្ថលេខា និង ត្រា
ហៀង ចណ្ណារក្ខី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៨/៩៥ កធស.ប្រក
ស្តីពីការយល់ព្រមបញ្ចូលមន្ត្រី រាជការក្នុង
ក្របខ័ណ្ឌមន្ទីរធម្មការ ខេត្ត តាកែវ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

-បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។

-បានឃើញប្រកាសលេខ ២៩៣ ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ក្រសួងមហាផ្ទៃ ។

សំរេច

ប្រការ ១ : យល់ព្រមបញ្ចូលមន្ត្រីរាជការចំនួន ១១ នាក់ក្នុងក្របខ័ណ្ឌមន្ទីរធម្មការ និង សាសនា ខេត្ត តាកែវ ដូចមានរាយនាមខាងក្រោម :

១-លោក គង់ ម៉ាក

២-លោក ខឹម ជេក

៣-លោក ខែក ឆន

៤-លោក សេក ចេន

៥-លោក ហ៊ុយ សំអឿន

៦-លោក នន ទី

៧-លោក ធេព ប៊ុន

៨-លោក សាំង សារិន

៩-លោក សុខ សាមណ្ណ

១០-លោក អ៊ួង ឡេង

១១-លោក ស៊ីម សុន

១២_លោក **ម៉ុក គុខ**

១៣_លោក **ចាន់ សន**

១៤_លោក **ស្វួន ភន**

១៥_លោក **ព្រុំព្រាប**

១៦_លោក **ញ៉ៃ ឆាន់**

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការដែលមានឈ្មោះខាងលើ អាស្រ័យដោយមន្ទីរធម្មការ និង សាសនា ខេត្តតាកែវ ជាអ្នករៀបចំ ។

ប្រការ ៣ : ក្រសួងធម្មការ និង សាសនា មន្ទីរធម្មការ និង សាសនា ខេត្តតាកែវ និងអស់លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៤ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និង ត្រា

ហៀន ចណ្ណាស៊ី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសអន្តរក្រសួងលេខ ១០០ ប្រក.កសក ស្តីពីការកំណត់ថ្លៃឈើឈរ និងថ្លៃលក់ និងឈើតាមទាក់ប្រកនាំចេញ

-ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ [illegible] ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

_បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញសេចក្តីសំរេចលេខ ០៥ សសរ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីនិតិវិធីនាំចេញឈើមូល_ឈើអារ និង ឈើកែច្នៃ ទៅបរទេស

_យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួងនាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ នៅនាយកដ្ឋានរុក្ខាប្រមាញ់

សំរេច

ប្រការ ១ : កំណត់ថ្លៃឈើឈរ ដោយយកថ្លៃឈើលេខ ២ ជាមូលដ្ឋានដូចខាងក្រោម :

ថ្លៃឈើមូលចាស់ :

ឈើលេខ ២ ថ្លៃ ២៩ ដុល្លារអាមេរិក ក្នុង ១ ម៉ែត្រគូប

_ឈើលេខ ១ ថ្លៃ ២៩ ដុល្លារអាមេរិក ក្នុង ១ ម៉ែត្រគូប គុណ ១,៥ = ៤៣,៥ ដុល្លារអាមេរិក

_ឈើលេខ ៣ ថ្លៃ ២៩ ដុល្លារអាមេរិក ក្នុង ១ ម៉ែត្រគូប គុណ ០,៨ = ២៣,៥០ ដុល្លារអាមេរិក

_ឈើក្រៅលំដាប់ថ្នាក់ ថ្លៃ ២៩ ដុល្លារអាមេរិកក្នុង ១ម៉ែត្រគូប គុណ ០,៥ = ១៤.៥០ ដុល្លារអាមេរិក

_ឈើប្រណិត (ធ្នង់) ថ្លៃ ២៩ ដុល្លារអាមេរិកក្នុង ១ម៉ែត្រគូប គុណ ៣,៥ = ១០១,៥០ ដុល្លារអាមេរិក

_ឈើប្រណិត (បេង) ថ្លៃ ១០១,៥ ដុល្លារអាមេរិកក្នុង ១ម៉ែត្រគូប គុណ ០,៨ = ៨១,២០ ដុល្លារអាមេរិក

_ឈើប្រណិត (នាងនួន.ក្រញូង) ថ្លៃ ១០១,៥ ដុល្លារអាមេរិកក្នុង ១ម៉ែត្រគូប គុណ ១,៥ = ១៥២,២៥ ដុល្លារអាមេរិក

១.២ ថ្លៃឈើមូលថ្មី :

_ឈើលេខ ២ ថ្លៃ ៤០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគូប

_ឈើលេខ ១ ថ្លៃ ៤០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគូប គុណ ១,៥ = ៦០ ដុល្លារអាមេរិក

_ឈើលេខ ៣ ថ្លៃ ៤០ ដុល្លារអាមេរិកក្នុង ១ម៉ែត្រគូប គុណ ០,៨ = ៣២ ដុល្លារអាមេរិក

_ឈើក្រៅលំដាប់ថ្នាក់ ថ្លៃ ៤០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគូប គុណ ០,៥ = ២០ ដុល្លារអាមេរិក

-ឈើប្រណិត (ធ្នង់) ថ្លៃ ៤០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ៣,៥ = ១៤០ ដុល្លារអាមេរិក

-ឈើប្រណិត (បេង) ថ្លៃ ១៤០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ១១២ ដុល្លារអាមេរិក

-ឈើប្រណិត (នាងនួន.ក្រញូង) ថ្លៃ ១៤០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ២១០ ដុល្លារអាមេរិក

១.៣ ថ្លៃឈើអារ (គិតទាំងឈើចាស់ទាំងឈើថ្មី) :

-ឈើលេខ ២ ថ្លៃ ៤២,៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ

-ឈើលេខ ១ ថ្លៃ ៤២,៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ៦៣,៧៥ ដុល្លារអាមេរិក

-ឈើលេខ ៣ ថ្លៃ ៤២,៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ៣៤ ដុល្លារអាមេរិក

-ឈើក្រៅលំដាប់ថ្នាក់ ថ្លៃ ៤២,៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៥ = ២១,២៥ ដុល្លារអាមេរិក

-ឈើប្រណិត (ធ្នង់) ថ្លៃ ៤២,៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ៣,៥ = ១៤៨,៧៥ ដុល្លារអាមេរិក

-ឈើប្រណិត (បេង) ថ្លៃ ១៤៨,៧៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ១១៩ ដុល្លារអាមេរិក

-ឈើប្រណិត (នាងនួន.ក្រញូង) ថ្លៃ ១៤៨,៧៥ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ២២៣,១២ ដុល្លារអាមេរិក

រូបភាព ២ : កំណត់ថ្លៃលក់-ទិញឈើតាមមាត់ច្រកនាំចេញ (FOB,FOT) សំរាប់គិតកំរៃសេវាកម្ម និង គិតពន្ធនាំចេញដោយយកថ្លៃ ឈើលេខ ២ ជាមូលដ្ឋានដូចខាងក្រោម :

២.១ ថ្លៃឈើមូល (គិតទាំងឈើចាស់ទាំងឈើថ្មី) :

-ឈើលេខ ២ ថ្លៃ ១៧០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ

-ឈើលេខ ១ ថ្លៃ ១៧០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ២៥៥ ដុល្លារអាមេរិក

-ឈើលេខ ៣ និង ក្រៅលំដាប់ថ្នាក់ថ្លៃ ១៧០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ១៣៦ ដុល្លារអាមេរិក

-ឈើប្រណិត (ធ្នង់) ថ្លៃ ១៧០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ៣ = ៥១០ ដុល្លារអាមេរិក

-ឈើប្រណិត (បេង) ថ្លៃ ៥១០ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ៤០៨ ដុល្លារអាមេរិក

-ឈើប្រណិត (នាងនួន.ក្រញូង) ថ្លៃ ៥១០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ៧៦៥ ដុល្លាអាមេរិក

២.២ ថ្លៃឈើអារ (គិតទាំងឈើចាស់ទាំងឈើថ្មី) ៖

-ឈើលេខ ២ ថ្លៃ ៣៤០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ

-ឈើលេខ ១ ថ្លៃ ៣៤០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ៥១០ ដុល្លាអាមេរិក

-ឈើលេខ ៣និងក្រៅលំដាប់ថ្នាក់ថ្លៃ ៣៤០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ២៧២ ដុល្លាអាមេរិក

-ឈើប្រណិត (ធ្នង់) ថ្លៃ ៣៤០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ៣ = ១.០២០ ដុល្លាអាមេរិក

-ឈើប្រណិត (បេង) ថ្លៃ ១.០២០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ០,៨ = ៨១៦ ដុល្លាអាមេរិក

-ឈើប្រណិត (នាងនួន.ក្រញូង) ថ្លៃ ១.០២០ ដុល្លាអាមេរិកក្នុង ១ ម៉ែត្រគ្រីគុណ គុណ ១,៥ = ១.៥៣០ ដុល្លា អាមេរិក

ប្រការ ៣ ៖ កំណត់កំរៃសេវាកម្ម និង ពន្ធនាំចេញដូចខាងក្រោម :

៣.១ កំរៃសេវាកម្ម ៖

-ឈើមូល ឬ ឈើអារ ១ ភាគរយលើថ្លៃលក់-ទិញឈើតាមមាត់ច្រកនាំចេញ ។

៣.២ ពន្ធនាំចេញ ៖

-ឈើមូល ឬ ឈើអារ ១០ ភាគរយលើថ្លៃលក់-ទិញឈើតាមមាត់ច្រកនាំចេញ ។

ប្រការ ៤ ៖ ក្នុងករណីថ្លៃឈើនៅលើទីផ្សារអន្តរជាតិកើនឡើងលើសពី ១០ (ដប់) ភាគរយ នៃថ្លៃឈើដែលបានកំណត់ក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវធ្វើការពិនិត្យកែប្រែឡើងវិញស្របតាម ថ្លៃឈើនៅលើទីផ្សារ អន្តរជាតិ ។

ប្រការ ៥ ៖ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ ៖ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ , ក្រសួងពាណិជ្ជកម្ម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួន។

ប្រការ ៧ ៖ ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងពាណិជ្ជកម្ម
ហត្ថលេខា និង ត្រា
ចម ប្រសិទ្ធ

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
ហត្ថលេខា និង ត្រា
តាវ សេងហួរ

បោះពុម្ពនៅរោងពុម្ពធិស្តិការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តំលៃ ៩៩៤ រៀល